# ក

## មាតិកា

## I_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


១៦-៨-២០០៤ -អនុក្រឹត្យលេខ ៣៧ អនក្រ.បក ស្តីពីការផ្ទេរអគារ ចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១៨៧០

១៦-៨-២០០៤ -អនុក្រឹត្យលេខ ៣៨ អនក្រ.បក ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ សម្បទា អោយមកបំរើការងារ នៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១៨៧២

១៩-៨-២០០៤ -អនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៧៥

១៩-៨-២០០៤ -អនុក្រឹត្យលេខ ៤៦៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៧៦

២០-៨-២០០៤ -អនុក្រឹត្យលេខ ៤៧០ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៨៧៧

២០-៨-២០០៤ -អនុក្រឹត្យលេខ ៤៧១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៧៨

២០-៨-២០០៤ -អនុក្រឹត្យលេខ ៤៧២ អនក្រ.តត ស្តីពីការតែងតាំងរដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ ១៨៧៩

២០-៨-២០០៤ -អនុក្រឹត្យលេខ ៤៧៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយទាហាន ១៨៨១

២០-៨-២០០៤ -អនុក្រឹត្យលេខ ៤៧៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ ពីឋានន្តរសក្តិអនុមន្ត្រី ទៅឋានន្តរសក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ១៨៨២

២៣-៨-២០០៤ -អនុក្រឹត្យលេខ ៤៧៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨៨៤

២៣-៨-២០០៤ -អនុក្រឹត្យលេខ ៤៧៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៨៥


### ២_សារាចរណែនាំ


២៣-៨-២០០៤ -សារាចរណែនាំលេខ ០៧ សរណន ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៥ ១៨៨៦


## II_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១៩-៨-២០០៤ -ប្រកាសលេខ១៥៨ MOC/M2004ស្តីពីការតែងតាំងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ១៩០៥

| | | |
|---|---|---|
| ១៩-៨-២០០៤ | -ប្រកាសលេខ ១៥៩ MOC/M2004 ស្តីពីនីតិវិធីចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក្កយប័ត្រពាណិជ្ជកម្ម,អាជ្ញាប័ណ្ណនាំចេញ | ១៩០៧ |
| ២៣-៨-២០០៤ | -ប្រកាសលេខ ១៦២ MOC/M2004 ស្តីពីការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | ១៩១១ |

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

| | | |
|---|---|---|
| ១៧-៨-២០០៤ | -ប្រកាសលេខ ៥៧៦ ឧរថ.អស.ប្រក ស្តីពីការបង្កើតគណៈកម្មាធិការសហប្រតិបត្តិការ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-ថៃ | ១៩១៣ |

## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

| | | |
|---|---|---|
| ២០-៨-២០០៤ | -ប្រកាសលេខ ២៦៣ ប្រក.កសក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន VANNY BIO-RESEARCH (CAMBODIA) CORPORATION LTD បង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជ និង ស្រាវជ្រាវសត្វ ស្វាក្តាមយកកូននាំចេញ | ១៩១៦ |

## ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

| | | |
|---|---|---|
| ២៣-៨-២០០៤ | -ប្រកាសលេខ ០២៨ អបស.មព ស្តីពីការផ្សព្វផ្សាយជាលក្ខណៈវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ | ១៩១៩ |

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

ការផ្ទេរអគារ ចលនទ្រព្យ អចលនទ្រព្យ

និងឯកសារពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន

អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤

## សម្រេច

### មាត្រា១ .-

ត្រូវបានផ្ទេរអគារ ព្រមទាំងចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ពន្ធ័របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានខាងក្រោមនេះ :

ក. គ្រឹះស្ថាន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ក្រសួងអប់រំ យុវជន និងកីឡា

ខ. គ្រឹះស្ថានបណ្តុះបណ្តាលនៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

គ. មជ្ឈមណ្ឌលបណ្តុះបណ្តាលនៃក្រសួងសាធារណការ និងដឹកជញ្ជូន

ឃ. មជ្ឈមណ្ឌលបណ្តុះបណ្តាលនៃអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**មាត្រា២ .-**

បែបបទនៃការផ្ទេរមន្ត្រីរាជការ ដែលមានចែងនៅក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តតាមនីតិវិធីជាធរមាន ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត-ក្រុងមានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រីស្តីទី**

**ស ខេង**

**ចំលងជូន:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយមកបំរើការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤

## សម្រេច

**មាត្រា១ ._**

ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយមកបំរើការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចខាងក្រោមនេះ ៖

ក. គ្រឹះស្ថាន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ក្រសួងអប់រំ យុវជន និងកីឡា

១- វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ( NTTI )

២- វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសមៈ

៣- វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ

៤- សាលាមធ្យមសិក្សាបច្ចេកទេសឫស្សីកែវ

៥- សាលាអប់រំបច្ចេកទេសវិជ្ជាជីវៈភ្នំពេញ

៦- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា-ជប៉ុន

៧- មជ្ឈមណ្ឌលបណ្តុះបណ្តាលមុខរបរសំណង់អគារ ( វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសមៈ )

៨- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល

៩- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ

១០-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត

១១-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្រុងព្រះសីហនុ

១២-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ

១៣-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្រុងកែប

១៤-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែង

១៥-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង

១៦-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម

១៧-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ

១៨-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប

១៩-សាលាការដ្ឋានសៀមរាប

២០-មជ្ឈមណ្ឌលកោសល្យវប្បកម្មជាតិ (CNS)

២១-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ

២២-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង (VTC)

២៣-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រៃកុនខ្លា

២៤-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង (PTC)

២៥-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិ៍សាត់

២៦-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង

២៧-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រចេះ

២៨-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង

២៩-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី

៣០-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្រុងប៉ៃលិន

៣១-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង

៣២- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ

ខ. គ្រឹះស្ថានបណ្តុះបណ្តាលនៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

- សាលាជាតិកសិកម្មកំពង់ចាម
- សាលាជាតិកសិកម្មព្រែកលៀប

គ. មជ្ឈមណ្ឌលបណ្តុះបណ្តាលនៃក្រសួងសាធារណការ និងដឹកជញ្ជូន

- សាលាបច្ចេកទេស JVC ភ្នំពេញ
- សាលាបច្ចេកទេស JVC ក្រុងព្រះសីហនុ

ឃ. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៃអតីតក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- សាលាបណ្តុះបណ្តាលវិជ្ជាជីវៈបឹងនិមល ស្រុកកំពង់បាយ ខេត្តកំពត
- សាលាបណ្តុះបណ្តាលវិជ្ជាជីវៈរលាំង ស្រុកបាកាន ខេត្តពោធិ៍សាត់

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រីស្តីទី**

ស ខេង

**ចំលងជូន:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៣

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## សំរេច

**មាត្រា ១** : តែងតាំងលោក **ខេត ឆន** ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និង ទំនាក់ទំនងអន្តរជាតិ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជំនួសលោក **ជា ផលរី** ដែលសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៤៧៨ អនក្រ - បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៧០៤ /០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ /នស /៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកប /០៦៩៩ /០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យ លេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

## សំរេច

**មាត្រា ១.-**

តែងតាំង :

១-លោក **ស៊ិន ទុន្នី** ជាអគ្គនាយករងកិច្ចការរដ្ឋបាល នៃក្រសួងធនធានទឹក និងឧតុនិយម ។

២-លោក **ម៉ិញ សច្ចៈ** ជាអគ្គនាយករងកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹក និងឧតុនិយម ដោយរក្សាក្របខ័ណ្ឌ និងឋានន្តរស័ក្តិនៅដដែល ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០០៤*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧០ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត /០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកឧត្តមសេនីយ៍ឯក **ទឹង សំណាង** អត្តលេខ ០០១២ បច្ចុប្បន្នជាអគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ទៅជាទីប្រឹក្សាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

២-លោកឧត្តមសេនីយ៍ឯក **សៅ វ៉ាទី** អត្តលេខ ០៤០៤ បច្ចុប្បន្នជាប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ទៅជាអគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*- ដូចមាត្រា ២*
*- ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨៧១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

### សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងមន្ត្រី ០២រូប ថ្នាក់នាយករង និងថ្នាក់ប្រធាននាយកដ្ឋាន របស់ក្រសួងផែនការ ដូចមានរាយនាមខាងក្រោម :

១-លោក **ហាស់ ប៊ុនថួន** ជានាយករង នៃវិទ្យាស្ថានជាតិស្ថិតិ

២-លោក **ហោ ដារិទ្ធ** ជាប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រជំរឿន និងអង្កេត នៃវិទ្យាស្ថានជាតិស្ថិតិ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧៨.អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងរដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធី សហប្រតិបត្តិការមហាអនុតំបន់មេគង្គ

**************

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ /០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការតែងតាំងរដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ

-បានឃើញសេចក្តីសំរេចលេខ ៤២ ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

-យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**មាត្រា១.-**

តែងតាំងឯកឧត្តម **ឃឹ តាំងលីម** ទេសរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គ ( GMS ) ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិ **ផ្កាយ់ចរសេនីយ៍ឯក** នាយទាហាននៃកងយោធពលខេមរភូមិន្ទជូន ÷

-លោកវរសេនីយ៍ទោ **សាយ សារុន** អត្តលេខ ០០០៨២០ មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងតាកែវ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវ អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ,ខែ សីហា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរស័ក្តិ

## ពីឋានន្តរស័ក្តិអនុមន្ត្រីទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវ ដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណោចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទិ ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០២/២៥៣ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការធ្វើសមាហរណកម្មទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

មាត្រា ១ .-

ត្រូវបានតម្លើងឋានន្តរស័ក្តិ ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងព្រះបរមរាជវាំង ដូចមានរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១ | លោក ហ៊ី សាម៉ន | ពីអនុមន្ត្រីថ្នាក់លេខ ៥ | ទៅវរមន្ត្រីថ្នាក់លេខ ១០ |
| ២ | លោក អូន សាយ | ពីអនុមន្ត្រីថ្នាក់លេខ ៧ | ទៅវរមន្ត្រីថ្នាក់លេខ ១០ |
| ៣ | លោក អ៊ិន វឌ្ឍសេរី | ពីអនុមន្ត្រីថ្នាក់លេខ ៧ | ទៅវរមន្ត្រីថ្នាក់លេខ ១០ |
| ៤ | លោក នួន វណ្ណៈ | ពីអនុមន្ត្រីថ្នាក់លេខ ៨ | ទៅវរមន្ត្រីថ្នាក់លេខ ១០ |
| ៥ | លោក ម៉ែន ទុន្នី | ពីអនុមន្ត្រីថ្នាក់លេខ ៩ | ទៅវរមន្ត្រីថ្នាក់លេខ ១០ |
| ៦ | លោក យឹម វីណារ៉ាទុច | ពីអនុមន្ត្រីថ្នាក់លេខ ១០ | ទៅវរមន្ត្រីថ្នាក់លេខ ១០ |

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "៣"*
- *ឯកសារ - កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ សាកលវិទ្យាធិការ នៃ សាកលវិទ្យាល័យ វិទ្យាសាស្ត្រ សុខាភិបាល

## សម្រេច

**មាត្រា១.**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនសាស្ត្រាចារ្យបរទេស ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការជួយបណ្តុះបណ្តាលសាស្ត្រាចារ្យ ទន្តបណ្ឌិត និង និស្សិត ព្រមទាំងជួយអភិវឌ្ឍន៍គុណភាពអប់រំ ធនធានមនុស្ស នៅមហាវិទ្យាល័យទន្តសាស្ត្រ ដូចមានរាយនាមខាងក្រោម :-

១-លោក SUNG HAN KIM ប្រធានក្រុមហ៊ុន Plantec , Inc នៃ សាធារណរដ្ឋកូរ៉េ

២-លោក M. PIENKOWSKI ប្រធានក្រុមហ៊ុន Trinon Titanium GmbH នៃ ប្រទេសអាល្លឺម៉ង់

**មាត្រា២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសុខាភិបាល និង សាកលវិទ្យាធិការ នៃ សាកលវិទ្យាល័យ វិទ្យាសាស្ត្រ សុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផល ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៧៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើ របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១.-**

តែងតាំងមន្ត្រី ដូចមានរាយនាមខាងក្រោម :

១. លោក **នួន ស៊ីផាន់** ជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី

២. លោក **កេត សោផាន់** ជាប្រធាននាយកដ្ឋានអាស៊ាន នៃទីស្តីការគណៈរដ្ឋមន្ត្រី

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ [illegible] ខែ សីហា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

សម្តេច ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ
~~~~~

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦៧ សជណណ

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៥

### I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៥

១. ឆ្នាំ ២០០៥ គឺជាឆ្នាំទី ២ នៃដំណើរការរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ និង ជាឆ្នាំទី ២ នៃការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ។ ឆ្នាំ ២០០៥ ខាងមុខនេះ គឺជាឆ្នាំប្រឈមនៃសេដ្ឋកិច្ចកម្ពុជា ។ ធៀបទៅនឹងសមិទ្ធិផលជាវិជ្ជមានគួរឱ្យកត់សំគាល់ តាមរយៈការសំរេចបាននូវកំណើនផលិតផលក្នុងស្រុកសរុប (ផសស) ក្នុងអត្រាជាមធ្យម ៦,៧៤% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំ នៃនីតិកាលទី ២ កន្លងទៅនេះ តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជា សំរាប់ឆ្នាំ ២០០៥-២០០៦ អាចធ្លាក់ចុះ (Slow-down) មកនៅក្នុងចន្លោះ ត្រឹមពី ២ ទៅ ៤% ប៉ុណ្ណោះ ។ ការព្យាករណ៍នេះ ផ្អែកលើកត្តាមិនអំណោយផលមួយចំនួន គឺ : (១)- មូលដ្ឋាននៃកំណើនក្នុងវិស័យកសិកម្ម នៅទន់ខ្សោយ ។ បន្ទាប់ពីកំណើនដ៏ខ្លាំងក្លានៅឆ្នាំ ២០០៣ និង កំណើនតិចតួចក្នុងឆ្នាំ ២០០៤ កំណើននៃវិស័យនេះ ហក់ឡើងតិចតួចប៉ុណ្ណោះ នៅក្នុងឆ្នាំ ២០០៥ ខាងមុខ ធៀបនឹងមូលដ្ឋានកំណើនដ៏ធំនៃឆ្នាំ ២០០៣ (២)- ភាពមិនច្បាស់លាស់សំរាប់វិស័យឧស្សាហកម្ម ពិសេសឧស្សាហកម្មកាត់ដេរ ផ្សាភ្ជាប់ទៅនឹងការបញ្ចប់ប្រព័ន្ធកូតា សំរាប់ការនាំ-ចេញសំលៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និន្នាការបន្តធ្លាក់ចុះនៃលំហូរវិនិយោគផ្ទាល់ពីបរទេស (FDI) ចូលមកកម្ពុជា ការឡើងថ្លៃប្រេងឥន្ធនៈ និង សភាពការណ៍អន្តរជាតិមិនសូវអំណោយផល (ការគំរាមកំហែងនៃភេរវកម្ម ចលាចល និង សង្គ្រាមនៅក្នុងតំបន់មួយចំនួន) ដែលអាចនឹងបង្កើតបច្ច័យអវិជ្ជមានគួរឱ្យបារម្ភសំរាប់វិស័យឧស្សាហកម្មកម្ពុជា នៅក្នុងឆ្នាំ ២០០៥-២០០៦ ខាងមុខ ទោះបីជាវិស័យទេសចរណ៍ ត្រូវបានរំពឹងទុកថា អាចនឹងបន្តស្ទុះងើបឡើងក៏ដោយ និង (៣)- លទ្ធភាពនៃការធ្លាក់ចុះជាបណ្តើរៗ នៃលំហូរជំនួយអភិវឌ្ឍន៍ផ្លូវការ ចូលមកក្នុងប្រទេសកម្ពុជា ដែលផ្សាភ្ជាប់ទៅនឹងបញ្ហាសេដ្ឋកិច្ច ហិរញ្ញវត្ថុ និង នយោបាយ

របស់បណ្តាប្រទេស និង អង្គការអ្នកផ្តល់ជំនួយផង និង ផ្សាភ្ជាប់ទៅនឹងល័ក្ខខ័ណ្ឌតំរូវកាន់តែខ្ពស់ឡើង ក្នុងការប្រកួតប្រជែងដើម្បីដណ្តើមជំនួយផង ។

២. ពិតណាស់ថា នៅចំពោះមុខសភាពការណ៍បែបនេះ រាជរដ្ឋាភិបាលបានដាក់ចេញ និង ជំរុញអនុវត្តយ៉ាងសកម្ម នូវកម្មវិធីកំណែទំរង់ដែលមានលក្ខណៈទូលំទូលាយ និង ស៊ីជំរៅ ពិសេសគឺ «យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដែលជារបៀបវារៈសេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវភាពប្រកួតប្រជែងរបស់កម្ពុជា និង ធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ ឈានចេញពីការប្រមូលផ្តុំការពឹងផ្អែកទៅលើតែវិស័យឧស្សាហកម្មកាត់ដេរ និង ទេសចរណ៍ឆ្ពោះទៅរកការពង្រីកមូលដ្ឋានសេដ្ឋកិច្ចឱ្យបានទូលាយ តាមរយៈការកែលំអអភិបាលកិច្ច ការពង្រឹងបរិស្ថានគ្របដណ្តប់ដែលអនុគ្រោះដល់ការអភិវឌ្ឍន៍គ្រប់ផ្នែក និងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព ដែលប្រមូលផ្តុំជាសំខាន់លើការអភិវឌ្ឍន៍វិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម ការអភិវឌ្ឍន៍វិស័យឯកជន និង ការងារ ការបន្តស្តារ និងកសាងបណ្តាញហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការអភិវឌ្ឍន៍ធនធានមនុស្ស ។

៣. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០០៥ គឺជាមធ្យោបាយដ៏សំខាន់បំផុតមួយ សំរាប់ឈានទៅសំរេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ ក្នុងន័យនេះ ក្រសួង- ស្ថាប័នដែលមានការ-ពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ពិសេសក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវប្រមូលផ្តុំរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៥ ឱ្យបានល្អប្រសើរ ដោយសំដៅបំពេញគោលដៅសំខាន់ៗដូចតទៅ ៖

- ធានាបំពេញប្រកបដោយប្រសិទ្ធភាព ដល់ការបន្តជំរុញកំណែទម្រង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាល នៅក្នុងគ្របវិស័យ ទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ជាពិសេសការអនុវត្តន៍ «កម្មវិធីនយោ-បាយរបស់រាជរដ្ឋាភិបាល និង «យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា ។
- ធានាបន្តបង្កលក្ខខណ្ឌអំណោយផលដល់ការរៀបចំ និង ដំណើរការគ្រប់គ្រងប្រទេសរបស់រាជ-រដ្ឋាភិបាលនីតិកាលទី ៣ ដើម្បីសំរេចបាននូវចក្ខុវិស័យនៃកំណើនពី ៦% ទៅ ៧% ក្នុងមួយឆ្នាំ និង ដើម្បីជំរុញនូវការអភិវឌ្ឍន៍ប្រកបដោយចិរភាព និង សមធម៌ ពិសេសតាមរយៈការបន្តជំរុញអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច ៥ ឆ្នាំលើកទី ២ (២០០១-២០០៥) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និង អភិវឌ្ឍន៍កម្មវិធីវិនិយោគសាធារណៈ (Public Investment Program – PIP) រំកិលបីឆ្នាំ ។
- បំពេញឱ្យការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការធានានូវតុល្យភាពថវិកា និង ទប់ស្កាត់អតិ-ផរណា ឱ្យស្ថិតនៅក្នុងកំរិតក្រោម ៥% ។
- ធានាពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុ ដល់ក្រុមប្រឹក្សាឃុំ- សង្កាត់ សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន ។

• បំពីឱ្យការខិតខំស្រូបទាញវិនិយោគទុនពីក្រៅប្រទេស ទាំងជាជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ទាំងជាទុនវិនិយោគផ្ទាល់ពីបរទេស (FDI) និង បំពីឱ្យការជំរុញជវភាពធុរកិច្ចក្នុងប្រទេស ។

៤. ទោះបីជាមានការយឺតយ៉ាវនៅក្នុងការចាប់ផ្តើមដំណើរការរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ ក៏ដោយ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៥ ដើម្បីដាក់សុំការអនុម័តពីសំណាក់ស្ថាប័ននីតិបញ្ញត្តិទាំងពីរ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៤ ខាងមុខនេះ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៥ ជាមួយក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ ចាប់ពីថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៤ នេះតទៅ ។

## II. ក្របខ័ណ្ឌថវិកាជាតិឆ្នាំ ២០០៥

### ២-១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០០៥ :

៥. ដោយលើបរិការណ៍រួមខាងលើ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសំរាប់ឆ្នាំ ២០០៥ ត្រូវបានកំណត់ _ដោយផ្អែកលើសេណារីយ៉ូប្រុងប្រយ័ត្នកំពូល_ ហើយមានសូចនាករសំខាន់ៗ ដូចតទៅ÷

- កំណើនសេដ្ឋកិច្ចតាមថ្លៃថេរ នឹងមានចំនួនប្រមាណ ៦% ដែលធ្វើឱ្យផលិតផលសរុបក្នុងស្រុក (ផសស) សំរេចបានចំនួនប្រមាណ ១៨.៨៨៧ ពាន់លានរៀល ឬត្រូវជាប្រមាណ ៤,៧ ពាន់លានដុល្លារ ។

- អតិផរណាត្រូវស្ថិតនៅក្រោម ៥% ដោយរាជរដ្ឋាភិបាលត្រូវបន្តអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង គោលនយោបាយរូបិយវត្ថុ ប្រុងប្រយ័ត្ន ។

- អត្រាប្តូរប្រាក់រៀល- ដុល្លារ នឹងស្ថិតនៅក្នុងរង្វង់ ៤.០៥០ រៀល ក្នុងមួយដុល្លារអាមេរិក ។

- បរិមាណរូបិយវត្ថុ នឹងកើនឡើងក្នុងចំនួនយ៉ាងច្រើន ២០% ។

- ឱនភាពគណនីចរន្ត នឹងកើនឡើងពី -១០,៨% នៃ ផសស ក្នុងឆ្នាំ ២០០៤ ដល់ -១១,៥% នៃ ផសស ក្នុងឆ្នាំ ២០០៥ ។

- ទុនបំរុងអន្តរជាតិសរុប នឹងបន្តកើនឡើង ដោយធានាបាននូវការនាំចូលចំនួន ៣ ខែ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចសហការជាមួយនឹងក្រសួងផែនការ និង ក្រសួង- ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីតាមដានជាប់ជាប្រចាំ និង វាយតម្លៃឡើងវិញលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិការណ៍នៃការត្រួតពិនិត្យការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុ នាពាក់កណ្តាលឆ្នាំ ២០០៥ ។

### ២-២. បញ្ហាប្រឈមក្នុងការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រង ២០០៥

៦. ជាមួយនឹងលទ្ធភាពធ្លាក់ចុះនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដូចបានពោលខាងលើ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងតែប្រឈមមុខនឹងបញ្ហាមួយចំនួនថែមទៀត នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជា

ពិសេសគឺ សមត្ថភាពមានកំរិតរបស់កម្ពុជាក្នុងការបង្កើនចំណូល ធៀបទៅនឹងការកើនឡើងជាលំដាប់នៃសេចក្តីត្រូវការខាងផ្នែកចំណាយ ។ សំរាប់ឆ្នាំ ២០០៥ ខាងមុខនេះ ការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ត្រូវជួបប្រទះបញ្ហាប្រឈមធំៗមួយចំនួនដូចខាងក្រោម ÷

ទីមួយ- ការបាត់បង់ចំណូលពីកំរ៉ៃគួតាអនុគ្រោះ និង ការបន្តធ្លាក់ចុះនៃចំណូលមិនមែនសារពើពន្ធ ។

ទីពីរ- បរិមាណបំណុលសាច់ប្រាក់ ដែលរដ្ឋជំពាក់អ្នកផ្គត់ផ្គង់ឯកជន នៅពុំទាន់បានកំណត់ឱ្យបានច្បាស់លាស់នៅឡើយ ដែលជាហេតុធ្វើឱ្យការគ្រប់គ្រងសាច់ប្រាក់ និង ការអនុវត្តន៍ថវិកានៅឆ្នាំ ២០០៥ នេះនៅតែជួបប្រទះការលំបាក ទោះជាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបាន និង កំពុងមានផែនការយុទ្ធសាស្ត្រ និង វិធានការជាក់ស្តែង ដើម្បីដាក់ឱ្យអនុវត្តក៏ដោយ ។

ទីបី- កាតព្វកិច្ចសងបំណុលជូនបណ្តាក្រុមហ៊ុន ដែលបានទទួលរងគ្រោះក្នុងព្រឹត្តិការណ៍នយោបាយឆ្នាំ ១៩៩៧ និង បណ្តាក្រុមហ៊ុនថៃ ព្រមទាំងរោងចក្រសហគ្រាសឯកជនមួយចំនួនទៀត ដែលបានទទួលការរងគ្រោះ ដោយសារបាតុកម្មហឹង្សានៅថ្ងៃ ទី ២៩ ខែ មករា ឆ្នាំ ២០០៣ ។

ទីបួន- ការកើនឡើងជាលំដាប់ ពីមួយឆ្នាំទៅមួយឆ្នាំ នូវកាតព្វកិច្ចសងប្រាក់កម្ចី ដែលរួមមានទាំងការប្រាក់ និង ប្រាក់ដើម ដល់ដៃគូអភិវឌ្ឍន៍ទាំងឡាយ ជាពិសេសឥណទានដែលបានខ្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ចាប់ពីឆ្នាំ ១៩៩២ មក ។ លើសពីនេះទៀត បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងបន្តការចរចាដោះស្រាយបញ្ហាបំណុលចាស់ជាមួយរុស្ស៊ី និង សហរដ្ឋអាមេរិក ហើយនៅពេលដែលការចរចានេះត្រូវបានបញ្ចប់ សេចក្តីត្រូវការចំណាយសម្រាប់ការសងបំណុលបរទេសនេះ នឹងកើនឡើងថែមទៀត ។

ទីប្រាំ- ការកើនឡើងនៃសេចក្តីត្រូវការចំណាយក្នុងវិស័យសង្គមកិច្ច និង ក្នុងការវិនិយោគសាធារណៈ ដើម្បីសំរេចឱ្យបានគោលដៅនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និង កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ។

## ២ - ៣ . ការជំរុញអនុវត្តន៍កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៧ . ដើម្បីដោះស្រាយបញ្ហាប្រឈមដ៏លំបាកស្មុគស្មាញទាំងអស់នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការចាំបាច់ទាំងឡាយ ដើម្បីសំអាត និង ពង្រឹងប្រព័ន្ធគ្រប់គ្រងថវិកាជាតិ តាមរយៈកម្មវិធីកំណែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) គ្រប់ជ្រុងជ្រោយមួយ ក្រោមការគាំទ្រ និង ឧបត្ថម្ភពីសំណាក់ដៃគូអភិវឌ្ឍន៍មួយក្រុមចំនួន ១០ ប្រទេស និង ស្ថាប័ន ដោយប្រើអភិក្រមគ្របដណ្តប់លើផ្ទៃវិស័យទាំងមូល (Sector-wide approach--SWAP) ។ ការអនុវត្តន៍កម្មវិធីនេះ ត្រូវបានគ្រោងសំរាប់រយៈពេលវែងដល់ឆ្នាំ ២០១៥ ដែលមានចែកចេញជាបួនដំណាក់កាល ហើយដំណាក់កាលទីមួយ ដែលផ្តោតអាទិភាពជាសំខាន់លើការធានាឱ្យ «ថវិកាជាតិមានលក្ខណៈអាចជឿទុកចិត្តបាន» ត្រូវចំណាយពេលអនុវត្តក្នុងរង្វង់ ១៥ ទៅ ២០ ខែ ខាងមុខនេះ ។ សំរាប់ដំណាក់កាលទីមួយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវដឹកនាំអនុវត្តការងារ

តាមចង្កោមអាទិភាពសំខាន់ៗចំនួន ៣៣ ដែលក្នុងនោះមានសកម្មភាពជាក់ស្តែងចំនួន ២០០ ។ យ៉ាងណាក៏ដោយ គួរកត់សំគាល់ថា គន្លឹះដ៏សំខាន់បំផុតនៅក្នុងកិច្ចការទាំងអស់នេះ គឺការពង្រឹងអភិបាលកិច្ច និង វិន័យក្នុងការគ្រប់គ្រងថវិកាជាតិ ក្នុងនោះត្រូវផ្តោតជាសំខាន់ទៅលើការប្រកាន់ និង អនុវត្តន៍យ៉ាងហ្មឹងម៉ាត់ និង ខ្ជាប់ខ្ជួន នូវវិន័យជប់យ៉ាង (ស៊ីលជប់) ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានកំណត់នៅក្នុង «យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាពនៅកម្ពុជា ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចលើកសំណើ និង វិធានការលំអិតជាក់ស្តែង ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និងអនុម័ត ហើយដាក់បទបញ្ជាឱ្យគ្រប់ក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**២-៤. គំរោងចំណូល-ចំណាយថវិកាជាតិឆ្នាំ ២០០៥ :**

២-៤-១. គំរោងចំណូលថវិកាក្នុងស្រុក:

*ក- ការកៀងគរចំណូលថវិកាក្នុងស្រុក*

៨. ថវិកាឆ្នាំ ២០០៥ មានគោលដៅបង្កើនចំណូលក្នុងស្រុកឱ្យស្មើនឹង ១២,៦៧% នៃ ផសស ។ តាមគោលដៅនេះ :

- ចំណូលចរន្ត ត្រូវសំរេចឱ្យបានក្នុងរង្វង់ចំនួន ២.៣៧៧.៦០០ លានរៀល (គណនាទាំងថវិកាខេត្ត-ក្រុងផង) គឺមានការកើនឡើងចំនួន ១៦,៨៣% បើប្រៀបធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ ២០០៤ ឬ ត្រូវជា ១២,៥៩% នៃ ផសស ។ ក្នុងនេះ÷

- ចំណូលសារពើពន្ធត្រូវសំរេចឱ្យបានក្នុងរង្វង់ចំនួន ១.៧៩៦.៦០០ លានរៀល (គណនាទាំងថវិកាខេត្ត-ក្រុងផង) គឺមានការកើនឡើង ២០,៦% បើប្រៀបធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ ២០០៤ ឬ ត្រូវជា ៩,៥១% នៃ ផសស ។

- ចំណូលពុំមែនសារពើពន្ធ ត្រូវសំរេចឱ្យបានក្នុងរង្វង់ចំនួន ៥៨១.០០០ លានរៀល (គណនាទាំងថវិកាខេត្ត-ក្រុងផង) គឺមានការកើនឡើង ៦,៣% បើប្រៀបធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ ២០០៤ ឬ ត្រូវជា ៣,០២% នៃ ផសស ។ គំរោងចំណូលពុំមែនសារពើពន្ធក្នុងឆ្នាំ ២០០៥ នេះ ទាបជាងគំរោងចំណូលពុំមែនសារពើពន្ធក្នុងឆ្នាំ ២០០៤ ដោយសារថវិកាជាតិបាត់បង់នូវប្រភពចំណូល ដែលបានមកពីកូតានាំចេញសំលៀកបំពាក់ទៅសហរដ្ឋអាមេរិក ។

*ខ- វិធានការពង្រឹងការប្រមូលចំណូលថវិកាឆ្នាំ ២០០៥*

៩. ដើម្បីសម្រេចបាននូវទិសដៅនៃគំរោងចំណូលថវិកាឆ្នាំ ២០០៥ ដូចបានគូសបញ្ជាក់ខាងលើ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង បណ្តាក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវខិតខំអនុវត្តវិធានការកៀងគរចំណូលសំខាន់ៗមួយចំនួន ដែលមានចែងក្នុងផែនការសកម្មភាព

សំរាប់ដំណាក់កាលទីមួយ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (PFM) ដូចខាងក្រោម ÷

*ទីមួយ- ការពង្រឹងសមត្ថភាពរបស់គ្រប់គ្រង និង ប្រមូលចំណូល :*

- កសាងបណ្តុំជំនាញនានា ដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការកសាងគោលនយោបាយ និង យន្តការគ្រប់គ្រងកម្មវិធីសមាហរណកម្មពេញលេញនៃការកៀងគរធនធានថវិកា ។
- បង្កើតក្របខ័ណ្ឌសំរាប់កៀងគរ និង បែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល និងផ្តល់ការណែនាំដល់ការកសាងវិធានការសំដៅបង្កើនធនធាននៅតាមខេត្ត និង ឃុំ ។
- កសាងបណ្តុំជំនាញសំរាប់រយៈពេលមធ្យម និង វែង ពាក់ព័ន្ធនឹងកម្មវិធីសមាហរណកម្មនៃការកៀងគរធនធានថវិកា សំដៅបំពេញការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។
- កសាងបណ្តុំជំនាញក្នុងការធ្វើសមាហរណកម្មការកៀងគរធនធានថវិកា ដើម្បីកំណត់បញ្ចូលទៅក្នុងដំណើរការកសាងថវិកាជាតិ និង ដំណើការត្រួតពិនិត្យឡើងវិញនៃការអនុវត្តន៍ថវិកាជាតិ ។
- កំណត់អោយបានច្បាស់លាស់នូវបំណុលពន្ធ និង បំណុលនៃចំណូលមិនមែនពន្ធដារ ដើម្បីរៀបចំផែនការប្រមូល និង តឹងទារអោយមានប្រសិទ្ធភាព ។
- ពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់សាមីក្រសួង- ស្ថាប័ននីមួយៗ ទាំងសវនកម្មផ្ទៃក្រៅ និង ការងារអធិការកិច្ច ទាំងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ទាំងអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើការគ្រប់គ្រងថវិកាជាតិ ជាពិសេសលើការប្រមូលចំណូល ។

*ទីពីរ- ការកៀងគរចំណូលផ្នែកពន្ធ និង ពន្ធគយ និង រដ្ឋាករ :*

- ពង្រឹងការប្រមូលពន្ធគយ តាមរយៈ (១)- ការជំរុញការអនុវត្តន៍ច្បាប់អោយបានហ្មឹងម៉ាត់ចំពោះអ្នកដែលមានប្រវត្តិមិនគោរពច្បាប់ និង ចំពោះប្រភេទទំនិញដែលមានហានិភ័យចំណូលខ្ពស់ និង (២)- ការពង្រឹងអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការទប់ស្កាត់ និង បង្ក្រាបអំពើរត់ពន្ធ ។
- អនុវត្តយុទ្ធសាស្ត្រចាប់បង្ខំ និង គោលការណ៍គ្រប់គ្រងហានិភ័យ ដើម្បីកាត់បន្ថយការរត់ពន្ធ និង បណ្តាសកម្មភាពខុសច្បាប់ផ្សេងៗនៅតាមព្រំដែន ។
- ពង្រឹងក្របខ័ណ្ឌគតិយុត្តិដោយផ្អែកលើច្បាប់គយថ្មី ដោយការអនុវត្តន៍យ៉ាងហ្មឹងម៉ាត់ ក្នុងនោះ រួមមានទាំងការកសាងគោលនយោបាយវិស័យគយ និង រដ្ឋាករ ការចងក្រងសេចក្តីណែនាំអនុវត្តនីតិវិធីគយ និង ការបណ្តុះបណ្តាលមន្ត្រីផងដែរ ។

- អនុវត្តកម្មវិធីគ្រប់គ្រងប្រជាយរបស់គយ ក្នុងការវិភាគលើចំណូល និង ការផ្តល់តួលេខចំណូល និង ស្ថិតិពាណិជ្ជកម្ម ប្រកបដោយបច្ចុប្បន្នភាព និង សុក្រិតភាព ។
- ជំរុញអនុវត្តគំរោងបំពាក់បច្ចេកវិទ្យាពត៌មានដល់ទីចាត់ការគយ និង រដ្ឋាករ ហើយរៀបចំវិធានការរយៈពេលខ្លីសំរាប់ការអនុវត្តន៍កម្មវិធីស្វ័យប្រវត្តិកម្មគយ រួមទាំងការរៀបចំបង្កើតមូលដ្ឋានច្បាប់ និង នីតិវិធីដែលមានការពាក់ព័ន្ធ និង ការបណ្តុះបណ្តាល និង ការរៀបចំគំរោងផង ។
- កំណត់ និង អនុវត្តវិធានការពង្រឹងស្ថាប័នគយ រួមទាំងការកែលំអរចនាសម្ព័ន្ធនៃការផ្តល់កំរៃ និង ការលើកទឹកចិត្តដល់មន្ត្រីគយ និង ការអភិវឌ្ឍន៍កម្មវិធីអភិបាលកិច្ចល្អផង ។

*ទីបី- ការកៀងគរចំណូលពន្ធដារ :*

- ពង្រឹងការប្រមូលចំណូលពន្ធ តាមរយៈការអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ ដែលមានការពាក់ព័ន្ធ ដូចជាច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង បទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។
- បន្តពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីករបបពិតនៅតាមបណ្តាខេត្ត- ក្រុងផ្សេងទៀត និង ពង្រឹងការអនុវត្តន៍អាករលើតំលៃបន្ថែម និង យន្តការបង្វិលសងអាករលើតម្លៃបន្ថែម ។
- កែលំអការវិភាគ និង ការព្យាករណ៍លើចំណូលពន្ធដារ ក្នុងទិសដៅបង្កើតបណ្តាជំរើសគោលនយោបាយថ្មីៗ ដើម្បីបង្កើនចំណូលពន្ធ ។
- កំណត់នីតិវិធីអោយបានច្បាស់លាស់ សំរាប់ពង្រឹងការផ្តល់ពត៌មានទៅវិញទៅមក ជាពិសេសពត៌មានអំពីអ្នកបង់ពន្ធប្រភេទធំ រវាងទីចាត់ការគយ និង រដ្ឋាករ និង នាយកដ្ឋានពន្ធដារ ។
- ការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងកិច្ចអតិបរមា ដើម្បីសំរួលដល់ការបង់ពន្ធ ជាពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម ។
- ពង្រឹងរដ្ឋបាលអាករពិសេស នៅនាយកដ្ឋានពន្ធដារ ។
- ពង្រឹងអោយបានគ្រប់ជ្រុងជ្រោយនូវសវនកម្មពន្ធ ពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម ។
- ពង្រឹងការគ្រប់គ្រងបំណុលពន្ធ និង អនុវត្តយ៉ាងហ្មត់ចត់នូវការតឹងទារបំណុលពន្ធដារ ក្នុងនោះរួមមាន ការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាពត៌មានសំរាប់កិច្ចប្រតិបត្តិការគ្រប់គ្រង និង ការធ្វើសវនកម្មពន្ធនៅនឹងកន្លែង ព្រមទាំងការជំរះបញ្ជីអ្នកជាប់ពន្ធផងដែរ ។
- បន្តអនុវត្តវិធានការពង្រឹងនាយកដ្ឋានពន្ធដារ រួមទាំងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការ-ជ្រើសរើសមន្ត្រីថ្មីបន្ថែម ការកែលំអសេវាបំរើអោយអ្នកជាប់ពន្ធ ការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាល ការធ្វើសវនកម្មផ្ទៃក្នុង ការបំពាក់នូវទេព្យសំភារៈចាំបាច់ផ្សេងៗ ។ល។

- បង្កើនការផ្ទៀងផ្ទាត់ពត៌មាន ដើម្បីស្វែងរកផលរបរនៅក្នុងរបបម៉ៅការដែលត្រូវផ្ទេរទៅរបបពិត ។

*ទីបួន- ការពង្រឹងការគ្រប់គ្រង និង ការកៀងគរចំណូលមិនមែនសារពើពន្ធ :*

- ដាក់ចេញនូវវិធានការជាបន្ទាន់ ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន សំរាប់ការគ្រប់គ្រង និង ប្រមូលចំណូលមិនមែនសារពើពន្ធ ។
- ពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។
- ពង្រឹងការគ្រប់គ្រងឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋ អោយស្របតាមច្បាប់ និង បទបញ្ញត្តិ ជាធរមាន ។
- ដាក់ចេញ និង អនុវត្តជាបន្ទាន់ឱ្យមានប្រសិទ្ធភាព នូវ : (១)-វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពីការជួល ឬ លក់អចលនទ្រព្យ រួមទាំងការពង្រឹងនីតិវិធីនៃការជួល និង ការចុះកិច្ចសន្យាផង (២)-វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីសហគ្រាសសាធារណៈ តាមរយៈការពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងសហគ្រាសទាំងអស់នោះ (៣)-វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពីការលក់ទំនិញសាធារណៈ និង ការផ្តល់សេវាសាធារណៈ និង (៤)-វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពីការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។
- ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងប្រមូលចំណូលពីអាជីវកម្មឆ្នោត និង ល្បែងភ្នាល់ផ្សេងៗ ដោយសិក្សាពីបទពិសោធន៍អន្តរជាតិ ពាក់ព័ន្ធនឹងជំពីសដែលអាចបង្កើនចំណូលពីអាជីវកម្មឆ្នោត និង ល្បែងភ្នាល់ទាំងអស់នោះ ។
- ពង្រឹងក្របខ័ណ្ឌច្បាប់ក្នុងការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការកាស៊ីណូ និង ពង្រឹងការប្រមូលចំណូលពីកាស៊ីណូ ឱ្យបានកើនឡើងសមស្របនឹងចំណូលជាក់ស្តែងនៃអាជីវកម្មក្នុងវិស័យនេះ ក្នុងនោះរួមមាន ការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និង មន្ត្រីដែលទទួលបន្ទុកការងារប្រមូលចំណូលនេះផងដែរ ។
- ដាក់ចេញ និង អនុវត្តនូវប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយលើរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និង ដើម្បីការពារផលប៉ះពាល់អាក្រក់ដល់ថវិកាជាតិ ។
- ដាក់ចេញ និង អនុវត្តជាបន្ទាន់ ឱ្យបានប្រកបដោយប្រសិទ្ធភាព នូវវិធានការដាក់វិន័យចំពោះក្រសួង-ស្ថាប័ន ឬ មន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ ដែលមិនព្រមបង់ចំណូលចូលរតនាគារជាតិ ឬ លួចលាក់ចំណូលទុកចាយនៅក្រៅបរិបថនៃថវិកាជាតិ ឬ ទុកចាយដោយខុសនីតិវិធីច្បាប់ជាធរមាន ។

- អនុវត្តយ៉ាងហ្មឹងម៉ាត់ និង ជាប់ជាប្រចាំនូវសវនកម្ម និង អធិការកិច្ច លើការអនុវត្តន៍កាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធរបស់គ្រប់ក្រសួង- ស្ថាប័ន និង សហគ្រាសសាធារណៈ ដែលមានការពាក់ព័ន្ធ ។

២-៤-២. គំរោងចំណាយថវិកាឆ្នាំ ២០០៥ :

*ក - ចំណាយចរន្តនៃថវិកាឆ្នាំ ២០០៥*

១០. ថវិកាឆ្នាំ ២០០៥ មានទិសដៅជាយុទ្ធសាស្ត្រ កំណត់ចំណាយចរន្តឱ្យស្ថិតក្នុងក៏រិតនៃធនធានដែលមាន គឺមានចំនួន ២.០៧៨.៦០០ លានរៀល (គិតចូលទាំងថវិកាខេត្ត- ក្រុងផង) ដែលមានការកើនឡើង ៩,០៤% បើប្រៀបធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ ២០០៤ និង ត្រូវជាប្រមាណ ១១% នៃ ផសស ។

១១. ថវិកាឆ្នាំ ២០០៥ ត្រូវបានបែងចែកតាមផ្នែកសំខាន់ៗ ដូចតទៅ ÷

- ចំណាយផ្នែកយោធា និង សន្តិសុខ មានចំនួនសរុប ៤៥២ ពាន់លានរៀល ឬ ស្មើនឹង ២,៣៩% នៃ ផសស ។

- ចំណាយផ្នែករដ្ឋបាលទូទៅ មានចំនួនសរុប ២៧១.៣៧៥ លានរៀល ឬ ស្មើនឹង ១,៤៤% នៃ ផសស ។

- ទន្ទឹមនឹងនេះ ចំណាយផ្នែករដ្ឋបាលសង្គមកិច្ចនឹងបន្តកើនឡើង ដើម្បីអនុវត្តឱ្យបានសំរេចនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

- ក្នុងឆ្នាំ ២០០៥ នេះ គំរោងចំណាយថវិកាផ្នែករដ្ឋបាលសេដ្ឋកិច្ច មានចំណែកស្មើនឹង ៩,៦% នៃ ចំណាយចរន្ត ឬ ១,០៦% នៃ ផសស ។

- ស្របតាមការប្តេជ្ញាចិត្តដែលមានចែងនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ចំណាយថវិកានៃឆ្នាំ ២០០៥ នឹងមានរួមបញ្ចូលនូវការតំឡើងបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ និង កងកំលាំងប្រដាប់អាវុធចំនួន ១៥% ។

- ដើម្បីសំរេចបាននូវគោលដៅនៃការបង្កើនចំណាយសម្រាប់ការអភិវឌ្ឍន៍នៅទីជនបទ និងធ្វើឱ្យថវិកាក្លាយជាឧបករណ៍ដែលគួរទុកចិត្តបាន រាជរដ្ឋាភិបាលបន្តគោលនយោបាយកាត់បន្ថយបំណុលថវិកា ដែលកកស្ទះនៅរតនាគារជាតិ ដោយរក្សានូវចំណាយចរន្តរបស់គ្រប់ក្រសួង- ស្ថាប័នទាំងអស់ឱ្យស្មើនឹងថវិកា ដែលអនុវត្តបានក្នុងឆ្នាំ ២០០៤ នេះ ។

១២. ថវិកាឆ្នាំ ២០០៥ ត្រូវបានបែងចែកតាមជំពូកសំខាន់ៗ ដូចតទៅ ÷

- ជំពូក ១២ ប្រាក់ឧបត្ថម្ភដំណើរការអង្គការសាធារណៈរដ្ឋបាល ត្រូវបានគ្រោងគិតចំនួន ៩៥.០០០ លានរៀល គឺសំរាប់ ÷

+ ឧបត្ថម្ភថវិកាខេត្ត- ក្រុង ចំនួន ................................ ៣៧.០០០ លានរៀល

+ ឧបត្ថម្ភថវិកាឃុំ- សង្កាត់ ចំនួន ................................ ៥៨.០០០ លានរៀល

- ជំពូក ២០ ត្រូវបានគ្រោងគិត ចំនួន ៥០.០០០ លានរៀល ។

- ជំពូក ៤០ ចំណាយផ្សេងៗ ត្រូវបានគ្រោងទុកចំនួន ១៦១.៧០៥ លានរៀល ដែលក្នុងនោះមានរួមបញ្ចូលទាំងគំរោងថវិកាបដិភាគ សំរាប់កិច្ចដំណើរការនៃតុលាការពិសេសសំរាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហមផង ។

- ជំពូក ៤១ ចំណាយពុំបានគ្រោងទុក ត្រូវបានគ្រោងចំនួន ២០.០០០ លានរៀល ។

*ខ- គំរោងចំណាយជាមូលធនឆ្នាំ ២០០៥*

១៣. គំរោងចំណាយជាមូលធនឆ្នាំ ២០០៥ ត្រូវបានគ្រោងទុកចំនួន ១.១៨៥.០០០ លានរៀល ឬ ៦,២៧% នៃ ផសស ។ គម្រោងចំណាយជាមូលធននេះ ត្រូវបានបែងចែកដូចតទៅ÷

- គំរោងវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកមានចំនួន ៣៤៥.០០០ លានរៀល ឬ ១,៨៣% នៃ ផសស បើប្រៀបធៀបនឹងគំរោងថវិកាឆ្នាំ ២០០៤ មានការកើនឡើង ៦,១% ។ គំរោងវិនិយោគនេះ ត្រូវបានបែងចែកជា÷ គំរោងសាងសង់ និង ទព្វសម្ភារៈ ចំនួន ១៤៥.០០០ លានរៀល ថវិកាបដិភាគចំនួន ៨០ ពាន់លានរៀល និង ដោយមូលនិធិក្រៅប្រទេស ជាជំនួយទ្រទ្រង់ថវិកា ចំនួន ១២០.០០០ លានរៀល ។

- គំរោងវិនិយោគដោយហិរញ្ញប្បទានមកពីក្រៅប្រទេសផ្ទាល់ ដែលមិនឆ្លងកាត់រតនាគារ មានចំនួន ៧៥០.០០០ លានរៀល ឬ ៣,៩៧% នៃផសស ។ គំរោងវិនិយោគនេះ ត្រូវបានធ្វើហិរញ្ញប្បទានដោយជំនួយគំរោងការ ដែលគ្រប់គ្រងដោយម្ចាស់ជំនួយផ្ទាល់ ។

- គំរោងរំលោះបំណុល មានចំនួន ៩០.០០០ លានរៀល ឬ ០,៤៨% នៃ ផសស ។ គំរោងរំលោះបំណុលនេះ រួមមាន ៥០.០០០ លានរៀល សំរាប់រំលោះបំណុល និង ៤០.០០០ លានរៀល សំរាប់រំលោះអាណត្តិកសន្ទះនៅរតនាគារជាតិ ។

*គ- គំរោងចំណូល- ចំណាយថវិកាខេត្ត- ក្រុង ឆ្នាំ ២០០៥*

១៤. គំរោងចំណូល- ចំណាយថវិកាខេត្ត- ក្រុង ឆ្នាំ ២០០៥ ត្រូវបានកំណត់ជាកញ្ចប់ថវិកា ដូចខាងក្រោមនេះ÷

- ចំណូលចរន្តមានចំនួន ១០៣.០០០ លានរៀល គឺមានការកើនឡើង ១,៩៨% បើប្រៀបធៀបនឹងគំរោងថវិកាឆ្នាំ ២០០៤ (១០១.០០០ លានរៀល) ដែលរួមមាន ÷

  + ចំណូលសារពើពន្ធមានចំនួន ៥៥.០០០ លានរៀល គឺមានការកើនឡើង ១០% បើប្រៀបធៀបនឹងគំរោងថវិកាឆ្នាំ ២០០៤ (៥០.០០០ លានរៀល) ។
  + ចំណូលពុំមែនសារពើពន្ធមានចំនួន ១១.០០០ លានរៀល គឺស្មើនឹងគំរោងថវិកាឆ្នាំ ២០០៤ ។
  + ចំណូលឧបត្ថម្ភពីថវិការដ្ឋ មានចំនួន ៣៧.០០០ លានរៀល គឺមានការថយចុះ ៧,៥% បើប្រៀបធៀបនឹងគំរោងថវិកាឆ្នាំ ២០០៤ (៤០.០០០ លានរៀល) ។

- ចំណែកឯចំណាយចរន្ត មានចំនួន ១០៣.០០០ លានរៀល គឺស្មើនឹងចំណូលចរន្ត នឹងមានការកើនឡើង ១,៩៨% បើប្រៀបធៀបនឹងគំរោងថវិកាឆ្នាំ ២០០៤ ។

*<u>បញ្ជាក់:</u> ចំពោះគំរោងចំណូល- ចំណាយថវិកាលំអិតតាមខេត្ត-ក្រុងនីមួយៗ ត្រូវបានបង្ហាញក្នុងតារាងឧបសម្ព័ន្ធទី ៦ ដែលមានភ្ជាប់ជាមួយនេះ ។*

២- ៤- ៣. អាទិភាពក្នុងការគ្រប់គ្រងចំណាយថវិកាឆ្នាំ ២០០៥ :

**១៥.** ដើម្បីពង្រឹងមូលដ្ឋានសំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០០៥ និង ដើម្បីរក្សាស្ថិរភាពនៃហិរញ្ញវត្ថុសាធារណៈ និង ម៉ាក្រូសេដ្ឋកិច្ចជាតិ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបន្តជំរុញអនុវត្តវិធានការជាក់ស្តែងមួយចំនួនដូចតទៅ÷

*<u>ទីមួយ- ការគ្រប់គ្រងសាច់ប្រាក់ :</u>*

ការបើកផ្តល់សាច់ប្រាក់ ត្រូវអនុវត្តទៅតាមលំដាប់អាទិភាពដូចខាងក្រោម ÷

ក- <u>អាទិភាពទីមួយ ដែលត្រូវបើកផ្តល់ភ្លាមៗ រួមមាន</u> ÷

- ប្រាក់បៀវត្ស ការសងប្រាក់ដើម និង ការប្រាក់ បដិភាគក្នុងការអនុវត្តន៍គំរោង និង ប្រាក់បញ្ញើរបស់ស្ថាប័នផ្សេងៗ ។
- កម្មវិធីសកម្មភាពជាអាទិភាព (ជំពូក១៣-PAP) ជាពិសេស សំរាប់ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងសុខាភិបាល) ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសំរបសំរួលជាមួយនឹងក្រសួងអាទិភាពទាំងពីរនេះ ព្រមទាំងជាមួយដៃគូអ្នកផ្តល់ជំនួយ ដើម្បីពិនិត្យឡើងវិញអំពីការរៀបចំ និង អនុវត្តន៍កម្មវិធីសកម្មភាពជាអាទិភាពសម្រាប់ឆ្នាំ ២០០៤ នេះ ដើម្បីពង្រឹង និង កែលំអសំរាប់ឆ្នាំ ២០០៥ ជាពិសេស ដើម្បីចៀសវាងការផ្ទេរថវិកាដ៏ធំធេងពីឆ្នាំចាស់ ទៅអនុវត្តទៅក្នុងឆ្នាំថ្មីជាបន្តបន្ទាប់ ដូចករណីដែលបានកើតមាន ឡើងក្នុងរយៈពេលបីឆ្នាំកន្លងទៅ ។ ក្នុងករណីចាំបាច់ ត្រូវតម្រឹមថវិកា PAP មកទៅត្រឹមកំរិតមួយដែលអាចធានាបាននូវការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព ។
- គំរោងដែលបានឆ្លងកាត់ការដេញថ្លៃសាធារណៈត្រឹមត្រូវ ។
- ការទូទាត់ថ្លៃទឹក អគ្គិសនី និង ទូរស័ព្ទរបស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ។
- ជំពូក ៣០.០៣ មូលនិធិសម្រាប់ជួសជុល និង ថែទាំផ្លូវថ្នល់ ។

ខ- <u>អាទិភាពទី ២ ដែលត្រូវបើកផ្តល់បន្តិចម្តងៗ ជាបន្តបន្ទាប់ទៅតាមលេខរៀង</u> ÷

- ក្រសួងម្ចាស់គំរោង ដែលយកកងវិស្វកម្មជាអ្នកអនុវត្តន៍គំរោងហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងក្របខ័ណ្ឌនៃឥណទានថវិកាជំពូក ៥០.០១ ។
- ជំពូក ៥០ ផ្សេងៗទៀត ។

គ- អាទិភាពទី ៣ ដែលត្រូវបើកផ្តល់តាមកម្មវិធីសងបំណុល ក្នុងរយៈពេលមធ្យម រួមមាន : បំណុលសាច់ប្រាក់ជំពាក់ក្រុមហ៊ុន ដែលបានផ្គត់ផ្គង់ ឬ អនុវត្តគំរោងដោយមិនបានឆ្លងកាត់ការដេញថ្លៃជាសាធារណៈ ហើយដែលក្រុមហ៊ុនបានឯកភាពទទួលយកការទូទាត់តាមលទ្ធភាពថវិកាជាតិ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបន្តទូទាត់សងគំរោងប្រភេទនេះ តាមកម្មវិធីជាក់ស្តែងមួយសំរាប់ឆ្នាំ ២០០៥ ទៀត ។

*ទីពីរ- ការដោះស្រាយបញ្ហាបំណុលផ្សេងៗទៀត :*

ទន្ទឹមនឹងការដោះស្រាយទូទាត់បំណុលសាច់ប្រាក់សំរាប់អាណត្តិដែលកកស្ទះនៅរតនាគារជាតិ នៅមានបំណុលមួយចំនួនទៀត ដែលមានចាប់តាំងពីឆ្នាំ ២០០៣ មក ហើយត្រូវដោះស្រាយផងដែរ នៅក្នុងក្របខ័ណ្ឌនៃជំពូក ៥៣ (ចំណាយសងបំណុល) ដែលរួមមាន÷

- បំណុលសងការខូចខាតរបស់ក្រុមហ៊ុននានាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នយោបាយឆ្នាំ ១៩៩៧
- បំណុលសងការខូចខាតរបស់ក្រុមហ៊ុនឯកជន ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ថ្ងៃទី ២៩ មករា ឆ្នាំ ២០០៣ និង បំណុលសងការខូចខាតរបស់ក្រុមហ៊ុនមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍បាតុកម្មហិង្សានានា ក្នុងរយៈពេលកន្លងមក ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំកម្មវិធីដោះស្រាយជាជំហាននូវបំណុលប្រភេទនេះ នៅក្នុងក្របខ័ណ្ឌនៃថវិកាជំពូក ៥៣ ដែលមានត្រៀមចំណែកឥណទានចំនួន ៤០ ពាន់លានរៀល ពីក្នុងឥណទានសរុប ៩០ ពាន់លានរៀល សំរាប់ឆ្នាំ ២០០៥ ។

**១៦.** ទោះបីជាយ៉ាងណាក៏ដោយ វិធានការទាំងឡាយខាងលើនេះ អាចដោះស្រាយបញ្ហាដែលបាន និងកំពុងកើតមាន ក្នុងលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ប្រសិនបើពុំមានវិធានការម៉ឺងម៉ាត់ជាកញ្ចប់សំរាប់កែទំរង់ការគ្រប់គ្រងថវិកាជាតិនោះទេ ។ នៅក្នុងស្មារតីនេះ ដើម្បីបង្កើតឱ្យបាននូវលក្ខខ័ណ្ឌចាំបាច់ និង គ្រប់គ្រាន់សំរាប់ការគ្រប់គ្រងថវិកាជាតិឆ្នាំ ២០០៥ ប្រកបដោយប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំសារាចរណែនាំលំអិតមួយទៀត ស្តីពីវិធានការកែលំអការគ្រប់គ្រងថវិកាជាតិ ឆ្នាំ ២០០៥ សំរាប់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ហើយដាក់បទបញ្ជាឱ្យគ្រប់ក្រសួង និង ស្ថាប័នដែលមានការពាក់ព័ន្ធអនុវត្តយ៉ាងហ្មឹងម៉ាត់ ជាកាតព្វកិច្ចមិនអាចវិលងបាន ។

## III. ការអនុវត្តន៍កម្មវិធីវិមជ្ឈការហិរញ្ញវត្ថុ

**១៧.** រាជរដ្ឋាភិបាលបន្តពង្រឹងការការអនុវត្តន៍កម្មវិធីវិមជ្ឈការហិរញ្ញវត្ថុ ដើម្បីពង្រឹងសមត្ថភាពមូលដ្ឋាន ។ នៅក្នុងបរិការណ៍នេះ មូលនិធិថវិកាឃុំ- សង្កាត់ ឆ្នាំ ២០០៥ នឹងទទួលបាននូវការឧបត្ថម្ភពីថវិការដ្ឋប្រមាណ ៥៨ ពាន់លានរៀល ឬត្រូវជាប្រមាណ ២,៥២% នៃចំណូលចរន្តថវិការដ្ឋ ។ មូលនិធិថវិកាឃុំ- សង្កាត់ នឹងត្រូវប្រើប្រាស់សំរាប់បំពេញនូវភារកិច្ចដូចខាងក្រោម ÷

ទី១- រដ្ឋបាលទូទៅ នៅក្នុងឃុំ- សង្កាត់

ទី២- ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គមកិច្ចនៅក្នុងឃុំ- សង្កាត់ ។ និង

ទី៣- ការផ្តល់សេវាសាធារណៈនៅតាមមូលដ្ឋាន ។

១៨. ដើម្បីគ្រប់គ្រងថវិកានេះឱ្យមានតម្លាភាព រាជរដ្ឋាភិបាលនឹងបង្កើតក្រុមប្រឹក្សាភិបាលមូលនិធិថវិកាឃុំ- សង្កាត់ (Commune Fund Board-CFB) ដែលមានតំណាងមកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាប្រធាន និង តំណាងក្រសួងមហាផ្ទៃ ក្រសួងផែនការ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងតំណាង ៣រូបរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ជាសមាជិក ។ ការបង្កើតឡើងនូវកិច្ចដំណើរការនៃមូលនិធិឃុំ- សង្កាត់ នឹងលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ- សង្កាត់ និង រដ្ឋបាលឃុំ- សង្កាត់ ដែលត្រូវបានបង្កើតឡើងមកនេះ អាចពង្រឹងសមត្ថភាពស្ថាប័ន និង រៀបចំការគ្រប់គ្រងតាមមូលដ្ឋានឱ្យមានគណនេយ្យភាព តម្លាភាព និង ប្រសិទ្ធភាព ។ ប្រការនេះ ទាមទារឱ្យមានការពង្រឹងសមត្ថភាព និងការជួយគាំទ្រក្រុមប្រឹក្សាឃុំ- សង្កាត់ ។ ការពង្រឹងសមត្ថភាពនេះ មានសារៈសំខាន់ខ្លាំងណាស់ ក្នុងការផ្តល់សេវា រួមមានទាំងសេវាសង្គម ដល់ភូមិនានាផងដែរ ។ តាមរយៈកម្មវិធីវិមជ្ឈការនេះ រាជរដ្ឋាភិបាលនឹងផ្តល់ថវិកាដោយត្រង់ទៅឱ្យក្រុមប្រឹក្សាឃុំ- សង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ- សង្កាត់អាចកសាងផែនការ និង គ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានមួយផ្នែករបស់ខ្លួន ដោយខ្លួនឯងផ្ទាល់ ។

## IV. ការផ្សារភ្ជាប់ផែនការក្នុងរយៈពេលមធ្យម ជាមួយនឹងក្របខ័ណ្ឌថវិកា

១៩. ក្នុងគោលដៅកែលំអបន្ថែមនូវការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងឥណទាននៃកម្មវិធី និងឥណទានភ្ជាប់សន្យា សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ត្រូវមានគំរោងកម្មវិធីសំរាប់ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (Medium Term Expenditure Framework-MTEF) ដើម្បីផ្សាភ្ជាប់គោលដៅអភិវឌ្ឍន៍របស់ជាតិ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដូចធ្លាប់បានរៀបចំក្នុងឆ្នាំកន្លងមកដែរ ។ ទំរង់នៃថវិកាជាតិឆ្នាំ ២០០៥ មាននិន្នាការបញ្ចូលទាំងគំរោងកម្មវិធីចំណាយរយៈពេលមធ្យមដែលមានលក្ខណៈដូចខាងក្រោម ÷

- បន្តពង្រឹងការផ្សាភ្ជាប់ថវិកាប្រចាំឆ្នាំ ទៅនឹងគោលដៅនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គម កម្មវិធីវិនិយោគសាធារណៈ និង បណ្តាគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- ថវិកាឆ្នាំ ២០០៥ បានផ្អែកទៅលើការព្យាករណ៍សំរាប់រយៈពេលមធ្យម ដែលបានធ្វើ និងភ្ជាប់ជាឧបសម្ព័ន្ធទៅក្នុងថវិកាឆ្នាំ ២០០៤ និង បន្តធ្វើបច្ចុប្បន្នកម្ម និង ព្យាករណ៍សំរាប់រយៈពេលមធ្យម សំរាប់ឆ្នាំបន្តបន្ទាប់ ដែលនឹងត្រូវភ្ជាប់ជាឧបសម្ព័ន្ធទៅក្នុងថវិកាប្រចាំឆ្នាំ ២០០៥ នេះ ។
- ថវិកានេះ កំណត់នូវវិធីសាស្ត្រសំរាប់អនុវត្តនូវកម្មវិធី ទាំងខាងចំណាយវិនិយោគ ទាំងខាងចំណាយសម្រាប់ដំណើរការ ។
- ជាការពិត ការឈរលើមូលដ្ឋានគោលការណ៍ធ្វើថវិកាប្រចាំឆ្នាំ ធ្វើឱ្យការព្យាករណ៍សម្រាប់ឆ្នាំ ២០០៦ និង បណ្តាឆ្នាំបន្ទាប់ ពុំមានសុពលភាពគតិយុត្តិដូចថវិកាប្រចាំឆ្នាំទេ ។ ក៏ប៉ុន្តែ

ការព្យាករណ៍នេះ មិនត្រឹមតែជាមូលដ្ឋានសំរាប់ការរៀបចំថវិកាប្រចាំឆ្នាំឱ្យកាន់តែមានសុក្រិតភាព និង ប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងធ្វើឱ្យថវិកាក្លាយទៅជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលយ៉ាងពិតប្រាកដ ។

២០. ការកសាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនេះ នឹងត្រូវធ្វើឡើងនៅគ្រប់ក្រសួង- ស្ថាប័ន ។ ប៉ុន្តែ សំរាប់ឆ្នាំ ២០០៥ នេះ ត្រូវកសាងឱ្យបាន ជាពិសេសសំរាប់ក្រសួងអាទិភាពចំនួនបួន គឺក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងក្រសួងចំណាយធំៗមួយចំនួនទៀត រួមមាន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ទីស្តីការគណៈ-រដ្ឋមន្ត្រី និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## V. ការរៀបចំ និង ការចរចាគសំណើនានា

២១. គម្រោងថវិកាឆ្នាំ ២០០៥ ត្រូវតែគិតគូប្រមូលផ្តុំ និងបង្ហាញឡើងតាមនាយកដ្ឋាននីមួយៗ និង តាមមុខងារ ។

២២. ថវិកាកំពុងប្រព្រឹត្តទៅ (n-1) ឆ្នាំ ២០០៤ ដែលរដ្ឋសភា និង ព្រឹទ្ធសភាបានអនុម័ត (ប្រសិនបើអាចទាន់ពេលវេលា) ត្រូវកែសំរួលដើម្បីធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ២០០៥ (n) សំរាប់ឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបានល្អ ។ ប៉ុន្តែ ក្នុងករណីស្ថាប័ននីតិបញ្ញត្តិទាំងពីរ មិនបានអនុម័តលើថវិកាឆ្នាំ ២០០៤ មុនពេលនៃការចាប់ផ្តើមនៃការគ្រោងថវិកាឆ្នាំ ២០០៥ នោះ មូលដ្ឋានទិន្នន័យនៃឆ្នាំ ២០០៣ និង សេចក្តីព្រាងថវិកាឆ្នាំ ២០០៤ ត្រូវយកមកធ្វើជាមូលដ្ឋានសម្រាប់ដំណើរការរៀបចំថវិកាឆ្នាំ ២០០៥ ឱ្យបានទាន់ពេលវេលា ។ ក្នុងករណីដែលមានសកម្មភាពការងារដូចមុន ក្រសួង- ស្ថាប័នត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ សំរាប់ធ្វើជាមូលដ្ឋានដោយគ្រាន់តែសំរួលទៅតាមតម្រូវការចាំបាច់ ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម ÷

- ចលនាឥណទាន ដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា ÷
    - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀតដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង- ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត- ក្រុង មានការប្រែប្រួល ។
    - ការផ្ទេរឥណទានថវិកាបន្ថែម សំរាប់ផលប្រយោជន៍របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ។

- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំ ទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ល។

- នៅក្នុងគំនិតផ្តួចផ្តើមថ្មី ក្រសួង- ស្ថាប័នចំណាយ ពិសេសក្រសួងចំណាយធំៗទាំងបួនគឺ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចរៀបចំ និង លើក

ឡើងនូវកម្មវិធីការងារសំខាន់ៗរបស់ខ្លួន (ក្រៅពីសកម្មភាពដំណើរការធម្មតាប្រចាំថ្ងៃ) រួចផ្តល់លំដាប់អាទិភាពទៅលើបណ្តាសកម្មភាពទាំងនោះ សំរាប់ជាមូលដ្ឋាននៃការវិភាជន៍ថវិកាប្រចាំឆ្នាំ ។ ដោយឡែកក្រសួងដែលអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ត្រូវយកចិត្តទុកដាក់រៀបចំកម្មវិធីសកម្មភាពទាំងនេះ អោយបានច្បាស់លាស់ត្រឹមត្រូវ និង អោយបានរួចរាល់សំរាប់ការវិនិច្ឆ័យកញ្ចប់ថវិកាដែលត្រូវការ ។

២៣. គំរោងថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់ការស្នើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកាក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលងាយយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៤. មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ត្រូវរៀបចំសំណើថវិកានៃឆ្នាំនីមួយៗតាមរយៈក្រសួងដែលជាខ្សែបណ្តោយរបស់ខ្លួន មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ចាប់តាំងពីឆ្នាំ ២០០៥ នេះតទៅ ។

២៥. ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៦- បច្ចេកទេសវិភាគដទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសំរាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួនសម្រាប់ធ្វើជាមូលដ្ឋានគ្រោងគណនាសម្រាប់ឆ្នាំផែនការ ។

២៧. សរុបសេចក្តីមក ឥណទានថវិកាចាំបាច់របស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ត្រូវតែបំពេញទៅលើ :

- គោលដៅរបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ
- បណ្តាសកម្មភាពជាអាទិភាព ដែលបានកំណត់ច្បាស់លាស់របស់ខ្លួន
- កម្មវិធីដែលត្រូវចាប់ផ្តើម ឬបន្តអនុវត្ត
- មធ្យោបាយដំណើរការ និង
- វិធានការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

## VI. នីតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៥

### ក. ការគ្រោងគណនាចំណូលថវិកាឆ្នាំ ២០០៥ :

២៨. ការគ្រោងគណនាចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង

បណ្តាលក្នុងខណ្ឌនៃប្រភពធនធាន ដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវរៀបចំគំរោងចំណូលថវិការបស់ខ្លួនដូចតទៅ ÷

- ចំណូលសារពើពន្ធ ត្រូវគណនាដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷

- លទ្ធផល ដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
- ផលប៉ះពាល់នៃអតិផរណា មកលើមូលដ្ឋានពន្ធ
- ការប៉ាន់ស្មានលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
- ការប្រែប្រួល ដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រា
- មូលដ្ឋានប្រមូលពន្ធ និង ការបង្កើតពន្ធថ្មី ។
- ចំណូលបន្ថែមដែលសង្ឃឹមថា ប្រមូលបានដោយសារការពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ រដ្ឋបាលគយ គោលនយោបាយពន្ធដារ និង គយ និង ការធ្វើវិចារណកម្មសារពើពន្ធ ។

- ទន្ទឹមនឹងនេះ ចំណូលពុំមែនសារពើពន្ធ ត្រូវគណនាទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាជួលសេវាកម្ម និង ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាដើម ។ល។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិ ដែលសំរេចបាននៅក្នុងឆ្នាំកន្លងមក និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

**ខ- ការគ្រោងគណនាចំណាយថវិកាឆ្នាំ ២០០៥ :**

២៩. ការគ្រោងគណនាឥណទានថវិកាចំណាយ ត្រូវផ្តើមចេញពីតម្រូវការជាក់ស្តែង និង ដោយផ្ទាល់ ដោយផ្អែកទៅលើកត្តាដែលទាក់ទងនឹងចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតម្លៃសម្ភារៈនៃការផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់កន្លងមកដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជម្ងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សា សម្រាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួរលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកា សម្រាប់ការគ្រប់គ្រងកន្លងមក ។

៣០. ជាទូទៅ គំរោងចំណាយទាំងអស់ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ត្រូវតែមានការវិភាគយ៉ាងល្អិតល្អន់ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយ ដើម្បីពន្យល់តាមជំពូក តាមប្រការ ទៅតាមតារាងគំរូ ដូចធ្លាប់បានធ្វើកន្លងមក សំរាប់ធ្វើជាមូលដ្ឋាននៃការពិភាក្សា ។ ដោយឡែក សំរាប់ឆ្នាំ ២០០៥ នេះ ចំពោះថវិកាជំពូក ១១ ដែលជាជំពូកប្រមូលផ្តុំលើចំណាយសំភារៈ និង ការគ្រប់គ្រងរដ្ឋបាលចាំបាច់ សំរាប់ដំណើរការរបស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវតែមានភ្ជាប់មកជាមួយនូវលិខិតយុត្តិការស្របច្បាប់ ដើម្បីអោយឃើញនូវមូលហេតុនៃតម្រូវការជាក់ស្តែងរបស់បណ្តាទាយកដ្ឋាន និង អង្គភាពនៅក្រោមឱវាទ ។ ឈរលើស្មារតីសន្សំសំចៃ ចំណាយជំពូកនេះ នឹងត្រូវកាត់បន្ថយចំនួន ៦% យ៉ាងតិចបើប្រៀបធៀបទៅនឹងឆ្នាំ ២០០៤ ។

**គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៥ :**

៣១. រាជរដ្ឋាភិបាលបានកំណត់កញ្ចប់ថវិកាសម្រាប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ និង គោលនយោបាយថវិកា ហើយ ដែលកញ្ចប់ថវិកាឆ្នាំ ២០០៥ នេះ មិនមានការប្រែប្រួលច្រើនឡើយ បើប្រៀបធៀបនឹងកញ្ចប់ថវិកាឆ្នាំ ២០០៤ ។ ជារួម ចំណាយចរន្តនៃថវិកាឆ្នាំ ២០០៥ ត្រូវបានបែងចែកតាមគោលដៅដូចខាងក្រោម÷

- ការបង្កើនចំណាយសំរាប់ពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុម- ប្រឹក្សាឃុំ- សង្កាត់ សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន ។
- ការបង្កើនចំណាយសម្រាប់ក្រសួងអាទិភាពទាំងបួន ។
- ការត្រៀមឥណទានថវិកាសម្រាប់សងបំណុលសំខាន់ៗមួយចំនួន ។

៣២. ដូច្នេះ កញ្ចប់ថវិកានេះ គឺជាលទ្ធភាពថវិកាខ្ពស់បំផុតនៃគំរោងចំណាយចរន្ត សំរាប់ផ្តល់ជូន ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញតាមខេត្ត- ក្រុងនីមួយៗ បែងចែកលំអិតទៅតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌនៃមាតិកាថវិកា និងដោយផ្អែកលើកម្មវិធីសកម្មភាព និងផែនការអាទិភាពស្នូល និងជាយុទ្ធសាស្ត្រ របស់ខ្លួនសំរាប់ឆ្នាំ ២០០៥ ដើម្បីឱ្យបានស្របតាមតម្រូវការប្រើប្រាស់ជាក់ស្តែង ពីព្រោះ ក្នុងរយៈពេលអនុវត្ត ថវិកានៃត្រីមាសទី ១ ឆ្នាំ ២០០៥ នេះ នឹងមិនអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញនៅតាមខេត្ត- ក្រុងទេ ។

៣៣. ប្រការដែលត្រូវយកចិត្តទុកដាក់ ក្នុងការបែងចែកកញ្ចប់ថវិកាឆ្នាំ ២០០៥ នេះ មានដូចតទៅ÷

- ចំណាយបៀវត្ស ត្រូវគ្រោងគិតទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទំរង់ រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការ ដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៤ ។ ចំនួន មន្ត្រីរាជការ ដែលលើសត្រូវមានសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ដោយផ្អែកតាមសំណើ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង មានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណភាព ត្រូវកាត់បន្ថយពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មាន មន្ត្រីថ្មី ត្រូវគ្រោងដោយឡែកក្នុងថវិកាសរុបនៃជំពូក ១០ ។ ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញ ខេត្ត- ក្រុង មិនត្រូវគណនាអតិរេកណា ក្នុងចំណាយថវិកាជំពូក ១០ នេះទេ ។ ចំពោះបុគ្គលិក អណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវស្នើសុំ ការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាត ឱ្យក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។ ការតម្លើង ប្រាក់បៀវត្សមូលដ្ឋានជាមធ្យមចំនួន ១៥% តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នឹង ត្រូវធ្វើការសំរេចដោយប្រើមូលនិធិបម្រុងចំនួន ៣៤ ពាន់លានរៀល ។

- ចំណាយដំណើរការរដ្ឋបាលទិញសំភារៈ និង ការជួសជុលតូច ត្រូវតែគ្រោងទុកប្រកបដោយលក្ខណៈត្បិតត្បៀត សន្សំសំចៃ និង ត្រូវពឹងផ្អែកទៅតាមកម្មវិធីសកម្មភាព និង ធម្មនិយាមដូចមានចែងខាងលើ ដើម្បីតម្រឹមអោយនៅក្នុងកញ្ចប់ថវិកានេះ ។ ត្រូវយកចិត្តទុកដាក់គណនាសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវ ដើម្បីគ្រប់គ្រងចំណាយទាំងនេះ នៅក្នុងលក្ខខ័ណ្ឌសន្សំសំចៃបំផុត ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនឱ្យមានចំណាយលើសពីឥណទានថវិកាដែលបានគ្រោងសម្រាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬ សេវា មកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។
- ចំណាយជំពូកផ្សេងៗទៀត ត្រូវគ្រោងទៅតាមការចាំបាច់ និង ត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកានេះ ។

៣៤. កញ្ចប់ថវិកា គឺជាកម្មវត្ថុនៃការពិភាក្សាក្នុងកិច្ចប្រជុំការពារថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ។ ការពិភាក្សាថវិកានេះ គឺគ្រាន់តែជាការពិភាក្សាបែងចែកថវិកាទៅតាមជំពូកតែប៉ុណ្ណោះ ។ ដូច្នេះ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវកសាងគំរោងថវិកាមិនឱ្យលើសតួរលេខនៃកញ្ចប់ថវិកានេះទេ ។ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងណាមួយ ដែលបានកសាងលើសកញ្ចប់ថវិកានេះ នឹងត្រូវកាត់ចេញចំនួនដែលលើសនោះ មុននឹងចាប់ផ្តើមធ្វើការពិភាក្សា ។ ចំពោះក្រសួងអាទិភាពទាំងបួន ដែលមានកម្មវិធីអភិវឌ្ឍន៍ស្រុកឈានមុខ (ADD) និង កម្មវិធីសកម្មភាពជាអាទិភាព (PAP) ការពិភាក្សាលើគំរោងចំណាយនេះ ត្រូវធ្វើឡើងដោយឡែក ដោយផ្អែកលើកម្មវិធីជាក់ស្តែងទាំងនេះ ដែលក្រសួងស្ថាប័នសាមី ត្រូវរៀបចំអោយបានហើយរួចរាល់មុនការអនុម័តថវិកា ។ ចំណាយ សំរាប់កម្មវិធីអភិវឌ្ឍន៍ស្រុកឈានមុខ (ADD) ត្រូវកត់ត្រាចូលក្នុងជំពូក ១៣.០១ ។ ចំណែកឯចំណាយ សំរាប់កម្មវិធីជាអាទិភាព (PAP) ត្រូវកត់ត្រាចូលក្នុងជំពូក ១៣.០២ ។ ចំពោះកញ្ចប់ថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង គឺមានកំណត់នៅក្នុងលិខិតដែលជូនភ្ជាប់មកជាមួយនេះ ។

៣៥. ពេលទទួលសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំទុកដាក់នូវគំរោងចំណូល-ចំណាយថវិការបស់ខ្លួនសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច) ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ពីព្រោះ ការពិភាក្សា នឹងត្រូវចាប់ផ្តើមនៅថ្ងៃទី ១ ខែ កញ្ញា ដល់ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៤ នេះតទៅ ។ តួរលេខគំរោងចំណូល-ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគណនាត្រឹម 0.1 លានរៀល ។

**៣៦.** ក្នុងការអនុវត្តន៍សារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីជំនាញខេត្ត-ក្រុង មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវធ្វើការទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច) ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

  " *ដើម្បីជូនជ្រាប* "

- គ្រប់ក្រសួង- ស្ថាប័ន
- គ្រប់អភិបាលខេត្ត- ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត- ក្រុង

  " *ដើម្បីមុខការ* "

- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៤២ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/ រកស/ ០៦៩៩/ ០៣ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ. បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៤២៣ អនក្រ. តត ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិសំរាប់សភាពាណិជ្ជកម្មរាជធានីភ្នំពេញអាណត្តិទី ២

-យោងតាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

## សំរេច

**ប្រការ១:** តែងតាំងលោក **ហេង ហាំងម៉េង** ប្រធានក្រុមហ៊ុនផ្សារឡាក់គីគ្រុប និងលោក **Bretton G. Sciaroni** ប្រធានក្រុមហ៊ុនស្ការ៉ូនី អេន អាសូស៊ីអ៊ីត ជាទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ។

**ប្រការ២:** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ, អគ្គនាយកបច្ចេកទេស, អគ្គាធិការ, នាយិកាខុទ្ទកាល័យ, ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមីខ្លួនត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>ចម្លងជូន</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង

- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន

-ដូចប្រការ២ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile. (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com •
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 42(

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No ១៥៩ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## នីតិវិធី ចេញ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ

*******

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមស្មារតីអង្គប្រជុំអនុគណៈកម្មការសំរបសំរួលពាណិជ្ជកម្មដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ប្រារព្ធធ្វើនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កន្លងមក ។

## សំរេច

**ប្រការ ១ :** បែបបទនាំចេញទំនិញវាយនភ័ណ្ឌ និង ផលិតផលធ្វើពីស្បែក តាមប្រព័ន្ធអនុគ្រោះ MFN/GSP ត្រូវបានកំណត់ដូចខាងក្រោម :

ក- ការងារត្រួតពិនិត្យអធិការកិច្ច ផលិតកម្ម និង ផលិតផលនាំចេញធ្វើដោយមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្ម និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវបានដំណើរការរួមគ្នានៅតាមមូលដ្ឋានផលិតកម្មនៅក្រោយពេលទំនិញត្រូវបាននាំចេញរួចហើយ និង ទទួលបានឯកសារបញ្ជាក់ប្រភពដើមទំនិញ (C/O, C/I, និង E/L) ពីក្រសួងពាណិជ្ជកម្ម ។

ខ- របាយការណ៍ផលិតកម្ម និង ទំនិញនាំចេញមួយ ត្រូវបានធ្វើឡើង និង ចុះហត្ថលេខារួមគ្នាមកពី :

- មន្ត្រីអធិការកិច្ចទំនិញនៃក្រសួងឧស្សាហកម្ម ចំនួន ០១ រូប
- មន្ត្រីអធិការកិច្ចទំនិញនៃក្រសួងពាណិជ្ជកម្ម ចំនួន ០១ រូប ឬ ០២ រូបក្នុងករណីជាប់ Export License ។

គ- ដំណើរការអធិការកិច្ចនេះ គឺជាកាតព្វកិច្ចតំរូវអោយគ្រប់អ្នកនាំចេញត្រូវសហការណ៍ជាមួយមន្ត្រីទាំងពីរស្ថាប័ន ដើម្បីបញ្ជាក់ដំណើរផលិតកម្ម-សមត្ថភាពផលិតកម្ម-ការជួលផលិតធានាភាពសមស្របក្នុងការអនុវត្តន៏វិធានប្រភពដើមទំនិញ និង សំរាប់ជាមូលដ្ឋាននៃការចេញវិក័យប័ត្រពាណិជ្ជកម្ម (C/I) . វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និង អាជ្ញាប័ណ្ណនាំចេញ (E/L) នៅជំហាន បន្ទាប់ទៀត ។

ឃ- ដំណើរការស្នើសុំ វិក័យប័ត្រពាណិជ្ជកម្ម (C/I) . វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និង អាជ្ញាប័ណ្ណនាំចេញ (E/L) តាមមធ្យោបាយផ្លូវទឹក និង ផ្លូវអាកាសត្រូវភ្ជាប់មកជាមួយ នូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោមនេះ :

- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនាំចេញ នីហរ័ណ-អាហរ័ណ និង បង្រ្កាបការក្លែងបន្លំ "កាំកុងត្រូល" និងទីចាត់ការគយ និង រដ្ឋាករ ។
- អញ្ញាត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- វិក័យប័ត្រ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- កិច្ចសន្យាទិញលក់ (Sale Contract)
- ប្រតិវេទន៏ចេញពីកម្ពុជា (Cambodia Outward Declaration)
- មូលប្បទានប័ត្រសំរាប់សោហ៊ុយរដ្ឋបាល ឬ សំរាប់កំរៃ Quota នាំចេញ ឬកំរៃនាំចេញ ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile (855-23) 213288
URL : http://www.moc.gov.kh E-Mail champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile (855-23) 426396

**ប្រការ ២** : បែបបទនាំចេញខាងលើត្រូវកំណត់អោយបង់សោហ៊ុយរដ្ឋបាល និង កំរៃនាំចេញដូចខាងក្រោម :

- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O)
  - * ទំរង់ N (Form N) = ៣០ USD ក្នុង ០១ ច្បាប់
  - * ទំរង់ A (Form A) = ៥០ USD ក្នុង ០១ ច្បាប់
- អាជ្ញាប័ណ្ណនាំចេញ = ១៥,០០០ រៀល ក្នុង ០១ ច្បាប់
- វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice) = ១២០,០០០ រៀល ក្នុង ០១ ច្បាប់

ក្នុងករណីទំនិញដែលនាំចេញទៅកាន់សហគមន៍អឺរ៉ុប និង ប្រទេសក្រៅពីសហរដ្ឋអាមេរិក ត្រូវបង់ :

ក- លើទំនិញវាយនភ័ណ្ឌ និង សំលៀកបំពាក់ បរិមាណក្រោម ២,០០០ Pieces ឬ ស្បែកជើង បរិមាណក្រោម ២០០ គូរ គឺ :

- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O)
  ទំរង់ N (Form N) = ១០ ដុល្លាអាមេរិក ក្នុង ០១ ច្បាប់
- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O)
  ទំរង់ A (Form A) = ១៥ ដុល្លាអាមេរិក ក្នុង ០១ ច្បាប់

ខ- កំរៃលើវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញនាំចេញសំលៀកបំពាក់គ្រប់ប្រភេទ ទៅកាន់សហគមន៍អឺរ៉ុប និង ក្រៅសហគមន៍អឺរ៉ុប ស្មើរនឹង ០,១០ ដុល្លាអាមេរិក / ឡូតិ៍ ។

**ប្រការ ៣** : ចាប់ពីពេលដាក់ពាក្យស្នើសុំ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ឬ នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស រហូតដល់ការប្រគល់ឯកសារ វិក័យប័ត្រពាណិជ្ជកម្ម (C/I), វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និងអាជ្ញាប័ណ្ណនាំចេញ (E/L) មានរយៈពេល ១១ ម៉ោង ៥៥ នាទី ។

**ប្រការ ៤** : កំណត់សុពលភាពនៃការប្រើប្រាស់ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ (By Air) មានរយៈពេល ៣០ ថ្ងៃ ( សាមសិបថ្ងៃ ) ។

**ប្រការ ៥** : នៅកន្លែងទទួលពាក្យរបស់នាយកដ្ឋានអនុគ្រោះពាណិជ្ជកម្ម និង នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ត្រូវមានការចូលរួមសង្កេតការណ៍ពីសំណាក់មន្ត្រីអធិការកិច្ចនៃក្រសួងពាណិជ្ជកម្ម និង តំណាងសមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា (GMAC) ដើម្បីតាមដានការបញ្ជាក់ការចុះថ្ងៃ-ខែ និង ពេលវេលាលើបង្កាន់ដៃទទួលពាក្យ និង លើឯកសារប្រគល់-ទទួលសំណុំរឿង



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones (855-12) 933 323 / 881223 Facsimile: (855-23) 426396

ប៉ុន្តែមិនមានការជ្រៀតជ្រែកក្នុងកិច្ចការជំនាញរបស់នាយកដ្ឋានទេ ។

__ប្រការ__ ៦ : អគ្គាធិការ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានគាំពារផលិតកម្ម , នាយិកាខុទ្ទកាល័យ ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ ។

__ប្រការ__ ៧ : ប្រកាស និង លិខិតជូនដំណឹងដែលមានលក្ខណៈផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

__ចម្លងជូន__ :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សោ ខាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ស្ថានឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមអ្នកកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*File. Prakas on new procedure for the issuance of C/I, C/O and E/L*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

Ministry of Commerce

No ១៦៧ MOC / M 2004

ភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

# ស្ដីពី

# ការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងប្រកាសលេខ ៥១៤ សវវ-ថហ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្ដីពីការកំណត់អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬ ចេញវិញ្ញាបនប័ត្រផ្សេងៗ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-យោងតាមការចាំបាច់ក្នុងទិសដៅកែទំរង់វិស័យចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួង

## សំរេច

**ប្រការ ១ :** រាល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានបង្កើតឡើងនិងធ្វើពាណិជ្ជកិច្ច ហើយមិនទាន់បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវមានកាតព្វកិច្ចមកចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២ :** ដើម្បីធានាអះអាង និង ទទួលខុសត្រូវលើរាល់សំណុំលិខិតដែលខ្លួនបានបំពេញ ឬ ដែលខ្លួនត្រូវបំពេញ និង ផ្ដល់មកតំកល់ទុកនៅនាយកដ្ឋាននីតិកម្មក្រសួងពាណិជ្ជកម្ម អភិបាលម្នាក់ ឬ ម្ចាស់ហ៊ុនម្នាក់ ត្រូវមកចុះហត្ថលេខាដោយផ្ទាល់ដៃ នៅចំពោះមុខមន្ត្រីនាយកដ្ឋាននីតិកម្ម



Ministry of Commerce # 20 A & B Preah Norodom Boulevard. Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

បញ្ជាក់ថា រាល់សំណុំ លិខិតទាំងឡាយនេះ ពិតជាគ្រប់គ្រាន់ និង ត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើយ ព្រមទាំងបង់សោហ៊ុយចំណាយដោយផ្ទាល់ដៃនៅលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៣** : សោហ៊ុយចំណាយលើបែបបទ សុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម មានដូចខាងក្រោម :

| | |
|---|---|
| -អាករលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | : 70 USD ( ចិតសិបដុល្លារអាមេរិក ) |
| -ទម្រង់បែបបទសុំចុះបញ្ជីពាណិជ្ជកម្ម | : 30 USD ( សាមសិបដុល្លារអាមេរិក ) |
| -ឆែកឈ្មោះ | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -ផ្តល់អត្តលេខចុះបញ្ជី | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -សភាពាណិជ្ជកម្ម | : 20 USD ( ម្ភៃដុល្លារអាមេរិក ) |
| -ព្រឹត្តិប័ត្រពាណិជ្ជកម្ម | : 10 USD ( ដប់ដុល្លារអាមេរិក ) |
| -ធ្វើត្រា | : 12 USD ( ដប់ពីរដុល្លារអាមេរិក ) |
| -រាជកិច្ច | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -មន្ទីរពាណិជ្ជកម្មក្រុងភ្នំពេញ | : 20 USD ( ម្ភៃដុល្លារអាមេរិក ) |

បូកសរុបសោហ៊ុយចំណាយលើបែបបទចុះបញ្ជី: 177 USD ( មួយរយចិតសិបប្រាំពីរដុល្លារអាមេរិក )

**ប្រការ ៤** : នាយកដ្ឋាននីតិកម្ម មានកាតព្វកិច្ចផ្តល់គំរូលក្ខន្តិកៈក្រុមហ៊ុនឱ្យអ្នកចុះបញ្ជី ។ ក្នុងករណីអ្នកចុះបញ្ជី ពឹងពាក់មេធាវី ឬក្រុមហ៊ុនច្បាប់ណាមួយជួយបំពេញ លក្ខន្តិកៈឱ្យខ្លួន សោហ៊ុយសេវានេះគឺស្ថិតនៅក្រៅវង្វង់អំណាចរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម ។ ក្រសួងពាណិជ្ជកម្មមិនទទួលខុសត្រូវលើសេវានោះទេ ។

**ប្រការ ៥** : នាយកដ្ឋាននីតិកម្ម ត្រូវមានវិធានការសមស្រប ដើម្បីសហការជាមួយអភិបាល ឬ ម្ចាស់ហ៊ុន ដែលមកសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដើម្បីជួយណែនាំ និង បង្កលក្ខណៈងាយស្រួលដល់ការចុះបញ្ជីពាណិជ្ជកម្មអោយបានឆាប់រហ័ស និង ទាន់ពេលវេលា ។

**ប្រការ ៦** : អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋាននីតិកម្ម និង មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់តាមខ្លឹមសារនៃប្រកាសនេះ ។

**ប្រការ ៧** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤តទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម-ប្រសិទ្ធ**

ចំលងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
-ទីស្តីការគណៈរដ្ឋមន្ត្រី ( ជូនជ្រាបជារបាយការណ៍ )
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
-ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ( ដើម្បីជួយផ្សព្វផ្សាយ )
-អភិបាលខេត្ត-ក្រុង ( ដើម្បីជួយផ្សព្វផ្សាយ )
-ឯកសារ-កាលប្បវត្តិ
-រាជកិច្ច ⁄

Prakas on commercial rigistration inspection/LAD/Sokun/SH

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៥៧៦ ឧរថ.បក.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៤

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសហប្រតិបត្តិការ កម្ពុជា_ឡាវ_មីយ៉ាន់ម៉ា_ថៃ

- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ៩៧៥ ឧរថ បល.ប្រក ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០០
- តាមស្មារតីនៃកិច្ចប្រជុំថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០០៣ ស្តីពីការរៀបចំគ្រប់គ្រងកិច្ចសហប្រតិបត្តិការបួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ។

## <u>សំរេច</u>

<u>**ប្រការ ១**</u> : បង្កើតគណៈកម្មាធិការមួយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ឯកឧត្តម | **ខ្លូត អ៊ាន់ឌី** | រដ្ឋលេខាធិការ | ជាប្រធាន |
| - ឯកឧត្តម | **ខួន នៅ** | អគ្គនាយកឧស្សាហកម្ម | ជាអនុប្រធាន |
| - ឯកឧត្តម | **សុទ ឌីគុណា** | អគ្គនាយកធនធានរ៉ែ | ជាអនុប្រធាន |
| - លោក | **ឱុន លាន** | អគ្គនាយករងថាមពល | ជាអនុប្រធាន |

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 855. 23 . 211141 Fax : 855 23 428263

- លោក **ស៊ិន សុណា** ប្រធាននាយកដ្ឋាន ជាសមាជិកអចិន្ត្រៃយ៍
- លោក **ស៊ឹម ណារ៉ា** ប្រធានការិយាល័យ ជាសមាជិក

**ប្រការ ២** : គណៈកម្មាធិការ មានអនុគណៈកម្មាធិការចំនួន ៣ ជាជំនួយការ :

ក. អនុគណៈកម្មាធិការឧស្សាហកម្ម មានសមាសភាព :

- ឯកឧត្តម **ខួន នេះ** អគ្គនាយកឧស្សាហកម្ម ប្រធាន
- លោក **កែវ សុវត្ថិ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ហូ ភាជីប** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ពីខ ស៊ីវឡាយ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **សាត សមុទ្រ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ជា តារា** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **នូវ ថារ៉ា** អនុប្រធាននាយកដ្ឋាន សមាជិក

ខ. អនុគណៈកម្មការភូគព្ភសាស្ត្រ រ៉ែ មានសមាសភាព :

- ឯកឧត្តម **សុទ ជីគុណ** អគ្គនាយកធនធានរ៉ែ ប្រធាន
- លោក **សៀង ស៊ីថាង** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ថ្វះ វិចិត្រ** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **យស់ មុនីរ៉ាត់** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **ម៉ក់ សុភត្រា** អនុប្រធាននាយកដ្ឋាន សមាជិក

គ. អនុគណៈកម្មការថាមពល មានសមាសភាព :

- លោក **នុន លាង** អគ្គនាយករង ប្រធាន
- លោក **ប៊ុន ណារិទ្ធ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **វិចន៍រ ហុស្សណា** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **តូច សុវណ្ណា** ប្រធានការិយាល័យ សមាជិក
- លោក **ហេង គុណលាង** ប្រធានការិយាល័យ សមាជិក
- លោក **នួន ចាន់ទ័ន់ដា** ប្រធានការិយាល័យ សមាជិក

**ប្រការ ៣** : គណៈកម្មាធិការនេះ ទទួលបន្ទុកលើការងារសហប្រតិបត្តិការបួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ទៅតាមស្មារតីនៃសេចក្តីប្រកាសរួម ស្តីពីកិច្ចសហប្រតិបត្តិការបួនប្រទេស ហើយមានភារកិច្ចដូចខាងក្រោម :

- លើកគំរោង និង ចរចាដោយផ្ទាល់ រវាងស្ថាប័នពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការបួនប្រទេស ដើម្បីជំរុញអនុវត្តផែនការសកម្មភាពបាហ្គាន ។
- តាមដាន និង ត្រួតពិនិត្យ រាល់ការអនុវត្តន៍គំរោងសហប្រតិបត្តិការបួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ។
- ចាត់ចែង រៀបចំកិច្ចប្រជុំ ក្នុង និង ក្រៅប្រទេស ។
- ធ្វើរបាយការណ៍អំពីដំណើរការ នៃការអនុវត្តន៍យុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ជូនថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ៤** : អនុគណៈកម្មាធិការ មានភារកិច្ចចរចាជាមួយក្រុមការងារ នៃប្រទេសដៃគូរ និង អនុវត្តគំរោងទាំងឡាយក្នុងកិច្ចសហប្រតិបត្តិការបួនប្រទេស និង ភារកិច្ចចាំបាច់នានា ដូចក្នុងប្រការ ៣ តាមការកំណត់របស់ប្រធានគណៈកម្មាធិការ តាម វិស័យរៀងៗ ខ្លួន ។

**ប្រការ ៥** : សមាជិកទាំងអស់នៃគណៈកម្មាធិការ និងអនុគណៈកម្មាធិការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៦** : អគ្គនាយកដ្ឋានឧស្សាហកម្ម អគ្គនាយកដ្ឋានធនធានរ៉ែ និង អគ្គនាយកដ្ឋានថាមពល នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ខុទ្ទកាល័យរដ្ឋមន្ត្រី និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ត្រូវអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន តាមប្រកាសនេះ ។

**ប្រការ ៧** : រាល់ប្រកាស ឬ កំណត់ចាត់ការទាំងឡាយពីមុន ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**ស៊ុយ សែម**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
 "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ២៦៣......ប្រក.កសក

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតឱ្យក្រុមហ៊ុន VANNY BIO-RESEARCH (CAMBODIA) CORPORATION LTD បង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជ និង ស្រាវជ្រាវសត្វស្វាក្តាមយកកូននាំចេញ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញលិខិតលេខ ១២៨៨ សជណ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យក្រុមហ៊ុន VANNY Bio-Research (Cambodia) Corporation LTD បង្កើតកសិដ្ឋាន ស្រាវជ្រាវបង្កាត់ពូជស្វាក្តាមមួយកន្លែង

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញពាក្យស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជ និងស្រាវជ្រាវសត្វស្វាក្ដាមកម្ពុជាយកកូននាំចេញរបស់ក្រុមហ៊ុន VANNY Bio-Research (Cambodia) Corporation LTD ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០០៤

## សម្រេច

**ប្រការ១** : អនុញ្ញាតឱ្យលោក LAU MAN SANG, JAMES ប្រធានក្រុមហ៊ុន VANNY BIO-RESEARCH (CAMBODIA) CORPORATION LTD បង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជ និងស្រាវជ្រាវសត្វស្វាក្ដាមកម្ពុជាមួយកន្លែងដើម្បីយកកូននាំចេញ ដែលមានផ្ទៃដីទំហំ ៤,២០ ហិកតា ស្ថិតនៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

**ប្រការ២** : សាមីកសិដ្ឋានដែលបានអនុញ្ញាតតាមប្រការ១ខាងលើ ត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌដូចខាងក្រោមៈ

ក-ត្រូវមានប្រព័ន្ធអេកូឡូស៊ីសមស្របនឹងលំនៅដ្ឋានកំណើតនៃសត្វស្វាក្ដាមដែលយកមកចិញ្ចឹម ។

ខ-ត្រូវធ្វើរបងហ៊ុមព័ទ្ធបរិវេណកសិដ្ឋាន ។

គ-ត្រូវរៀបចំទ្រុងឱ្យមានទំហំទូលាយតាមបច្ចេកទេសត្រឹមត្រូវអាចឱ្យសត្វធ្វើចលនាដោយសុវត្ថិភាព ។

ឃ-ត្រូវមានអនាម័យគ្រប់ពេលវេលាដើម្បីធានាដល់សុខុមាលភាពសត្វ និង មិនប៉ះពាល់បរិស្ថានជុំវិញ ។

ង-ត្រូវផ្តល់ចំណីអាហារដែលប្រកបដោយគុណភាពដើម្បីរក្សាបានសុខភាព និងការបន្តពូជ ។

ច-ត្រូវមានអ្នកឯកទេសបសុពេទ្យ ថ្នាំពេទ្យ ទូរក្សាថ្នាំពេទ្យ បន្ទប់ជួយសង្គ្រោះ ដើម្បីធានាការព្យាបាលសត្វស្វាក្ដាមជាប្រចាំ ។

ឆ-ការនាំសត្វស្វាក្ដាមចូលកសិដ្ឋាន ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានលិខិតអនុញ្ញាតដឹកជញ្ជូនពីសមត្ថកិច្ចជំនាញ ។

ជ-ការនាំចេញកូនស្វាក្ដាមត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវមានលិខិតនាំចេញពីសមត្ថកិច្ចជំនាញ ។

ឈ-ត្រូវសំរួលដល់មុខនាទីអាជ្ញាធរមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញ-ចូលធ្វើការត្រួតពិនិត្យសកម្មភាពកសិដ្ឋានគ្រប់ពេលវេលា ។

ញ-កសិដ្ឋានចិញ្ចឹមសត្វស្វាក្ដាម ត្រូវមានសៀវភៅបញ្ជីតាមដានសត្វស្វាក្ដាមចេញ-ចូលច្បាស់លាស់ ។

ដ-សត្វស្វាក្ដាមមេ បា និងកូនគ្រប់ជំនាន់ ត្រូវរៀបចំឱ្យមានពាក់ផ្លាកលេខសំគាល់ច្បាស់លាស់ ។

ឋ-ត្រូវទទួលខុសត្រូវលើគ្រប់បទល្មើសដែលកើតមានក្នុងបរិវេណកសិដ្ឋានសត្វស្វាក្ដាមរបស់ខ្លួន ។

ឌ-ការប្តូរឈ្មោះ ឬផ្ទេរកសិដ្ឋានសត្វស្វាក្ដាមពីអ្នកគ្រប់គ្រងមួយទៅមួយទៀត ត្រូវហាមឃាត់ជាដាច់ខាត ។

**ប្រការ៣** : ប្រកាសអនុញ្ញាតឱ្យបង្កើតកសិដ្ឋាននេះ នឹងត្រូវទុកជានិរាករណ៍ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីដែលយល់ឃើញថាបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរមានលក្ខណៈមិនរាងចាល បន្ទាប់ពីបានទទួលការព្រមាន ផាកពិន័យជាបន្តបន្ទាប់ ។

**ប្រការ៤** : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានរដ្ឋបាលព្រៃឈើ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តកណ្តាល និង ម្ចាស់កសិដ្ឋានសាមីត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០៤

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងបរិស្ថាន

-អាជ្ញាធរគ្រប់គ្រងសាយតេសកម្មជា

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ៤

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ: ០២៨ អបស.ម.៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៤

# ប្រកាស

ស្តីពី

## ការផ្សព្វផ្សាយជាលក្ខណៈវិជ្ជាជីវៈ ឯកជនក្នុង វិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ០៧ ២០០៤ ដែលប្រកាសអោយប្រើ ច្បាប់ធម្មនុញ្ញបន្ថែម ដើម្បីធានាដំណើរការទៀងទាត់ជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ០៧-២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣-១១-២០០០ ប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២០០/០៣៥ ចុះថ្ងៃទី ០១ ០២ ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០ ៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ១១-០៩-០២ ស្តីពីបែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតអោយជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យស្តីពីក្រមសីលធម៌គ្រូពេទ្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៣
- បានឃើញប្រកាសលេខ ០២០/០១ អបស/បក ចុះថ្ងៃទី ០៧-០៩-០១ របស់ក្រសួងសុខាភិបាលស្តីពីបែបបទនិងលក្ខខណ្ឌបច្ចេកទេស ក្នុងការសុំបើក ឬ បិទ សុំកែប្រែទំហំ ឬប្តូរទីតាំងនៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១.-** ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្ម របស់សេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង

ជំនួយវេជ្ជសាស្ត្រ តាមរយៈ វិទ្យុ-ទូរទស្សន៍-សារពត៌មាន-ទស្សនាវដ្ដី ព្រឹត្តិបត្រវេជ្ជសាស្ត្រ-ប័ណ្ណប្រកាសរូបភាព សិក្ខាសាលា- ប្រពន្ធ័អេឡិចត្រូនិច- ខិតប័ណ្ណចែកចាយតាមដងផ្លូវ- ការផ្សព្វផ្សាយពាណិជ្ជកម្មដោយប្រើឧគ្ឃោសនសព្ទតាមទីសាធារណៈ-រថយន្ត-រោងល្ខោន-រោងភាពយន្ត ផ្ទាំងប៉ាកាត់ ឬតាមរូបភាព ផ្សេងៗត្រូវហាមឃាត់ដាច់ខាត ។

**ប្រការ២.-** វិជ្ជាជីវវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ មិនត្រូវបានអនុញ្ញាតអោយលើកទៅឆ្លៃប្រឌិតធ្វើជាមុខជំនួញ ផ្ទាល់ខ្លួនណាមួយឡើយ ។ រូបភាពផ្សព្វផ្សាយដោយផ្ទាល់ ឬដោយប្រយោល ដែលបំផ្លើស ខុសការពិត ទាំងអស់ ត្រូវហាមឃាត់ ។

**ប្រការ៣.-** ហាមឃាត់ការផ្សព្វផ្សាយអំពីរោគសញ្ញាគ្លីនិក នៃជំងឺ និងវិធីព្យាបាលណាមួយ ដែលមានលក្ខណៈ បំផ្លើស បោកប្រាស់អតិថិជន ។

**ប្រការ៤.-** មិនអនុញ្ញាតអោយប្រើប្រាស់ ឈ្មោះមន្ទីរពេទ្យ ឬ គ្លីនិកឯកជន អ្នកឯកទេសណាមួយ ទោះបីជាបរទេសក្ដី ឬ ខ្មែរក្ដី ក្នុងរូបភាព ក្លែងបន្លំសហការជាមួយ ក្នុងទិសដៅឃោសនាផ្សព្វផ្សាយពាណិជ្ជកម្មឡើយ ។

**ប្រការ៥.-** បន្ទប់ពិគ្រោះព្យាបាលជំងឺ- បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ-បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក-បន្ទប់សោភ័ណ្ឌសល្យសាស្ត្រ មន្ទីរពិសោធន៍ មន្ទីរព្យាបាលជំងឺមាត់ធ្មេញ-មន្ទីរសំរាកព្យាបាល-មន្ទីរសម្ភព មន្ទីរពហុព្យាបាល និង មុខវិជ្ជាជីវៈប្រហាក់ប្រហែលផ្សេងទៀត អាចដាក់ពាក្យសុំធ្វើការផ្សព្វផ្សាយ បានលុះត្រាតែ ទីតាំងសេវានោះមាន ច្បាប់អនុញ្ញាត ឬបានចុះលេខបញ្ជិការ ព្រមទាំងមានឡូហ្គោសំគាល់ពីក្រសួង សុខាភិបាល ។

**ប្រការ៦.-** រាល់ការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈដែលមិនប៉ះពាល់ដល់ក្រមសីលធម៌គ្រូពេទ្យ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។ ម្ចាស់សេវាឯកជន ដែលមានបំណងផ្សព្វផ្សាយ ត្រូវដាក់ពាក្យស្នើសុំ មកក្រសួងសុខាភិបាល ដោយភ្ជាប់មកជាមួយនូវខ្លឹមសារអត្ថបទ ស្គ្រីវីដេអូ ឬ កាសែតសោតទស្សន៍ និងរូបភាព ដែលពាក់ព័ន្ធ និងការផ្សាយ ក្រោយពីបានឆ្លងកាត់ការត្រួតពិនិត្យ ផ្ដល់យោបល់ ជាមុន ពីសំណាក់ក្រុមប្រឹក្សា គណៈវិជ្ជាជីវៈនិមួយៗ នៃខេត្ត ក្រុង ។

**ប្រការ៧.-** សេវាឯកជនវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលមានបំណងផ្សព្វផ្សាយ តាមមធ្យោបាយ អ្វីក៏ដោយ ត្រូវប្រើពាក្យពេចន៍ដោយប្រុងប្រយ័ត្ន និង គិតទៅដល់ ប្រតិឃាត នៃពាក្យពេចន៍ របស់ខ្លួនចំពោះសាធារណៈជននិងក្រមសីលធម៌គ្រូពេទ្យ ជៀសវាងអំពើឃោសនា លើក

ដំកើងខ្លួន ប្រកួតប្រជែង ដើម្បីផ្តល់សេវាកម្មមួយទៀតសំរាប់ មូលហេតុអ្វីមួយ ដែលមិនមែនជាផលប្រយោជន៍សាធារណៈ ។

**ប្រការ៨.-** ខ្លឹមសារផ្សព្វផ្សាយ ត្រូវមានលក្ខណៈត្រឹមត្រូវ តាមឯកសារវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ និង ជៀសវាង ការឃោសនាបំផ្លើសប្រាស់ចាកខុសពីខ្លឹមសារ ដែលមានការយល់ព្រមអនុញ្ញាត ពីក្រុម-ប្រឹក្សា គណៈវិជ្ជាជីវនីមួយៗ នៃខេត្ត-ក្រុង និង ពីក្រសួងសុខាភិបាល ។

**ប្រការ៩.-** អាចអនុញ្ញាតអោយ សុំផ្សព្វផ្សាយបាន គឺ នៅពេលដែលមានការបើកទីតាំងថ្មី ឬ មានការផ្លាស់ប្តូរ ឬ បន្ថែមមុខជំនាញ ផ្លាស់ប្តូរទីតាំង។ អត្ថបទ និងរបៀបផ្សាយត្រូវផ្ញើរទៅក្រុមប្រឹក្សាគណៈវិជ្ជាជីវនីមួយៗ នៃខេត្ត ក្រុង ពិនិត្យជាមុនសិន ។

**ប្រការ១០.-** បន្ទាប់ពីបានឆ្លងកាត់ការត្រួតពិនិត្យរួច ក្រសួងសុខាភិបាលអាចអនុញ្ញាតអោយចុះផ្សាយជាសាធារណៈបានគឺ:

១-នាមត្រកូល អាស័យដ្ឋានវិជ្ជាជីវៈ លេខទូរស័ព្ទ និងលេខទូរសារ ថ្ងៃ និងម៉ោងមកជួប ពិគ្រោះព្យាបាល ។

២-គុណវុឌ្ឍិ សញ្ញាប័ត្រសិក្សាឯកទេស និងសមត្ថភាពផ្សេងៗ ទទួលស្គាល់ដោយ សាកល វិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល និងគណៈវិជ្ជាជីវនីមួយៗ ដែលមានការទទួលស្គាល់ ពីក្រសួងសុខាភិបាល ។

៣-ស្ថានភាពសេវា និងអ្នកផ្តល់សេវា ចំពោះក្រុមហ៊ុនធានារ៉ាប់រង បើមាន ។

៤-ព្រមទាំងខ្លឹមសារផ្សព្វផ្សាយផ្សេងៗទៀត ដែលមានផលប្រយោជន៍ដល់សង្គមជាតិ ។

**ប្រការ១១.-** រាល់លិខិតអនុញ្ញាតផ្សព្វផ្សាយ តាមគ្រប់រូបភាព មានសុពលភាពរយៈពេល ៦ ខែ គិតចាប់ ពីថ្ងៃចេញលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ១២.-** ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញនូវលិខិតអនុញ្ញាតផ្សព្វផ្សាយ ក្នុងករណីពិនិត្យ ឃើញថា :

ខ្លឹមសារផ្សព្វផ្សាយមានលក្ខណៈខុសពីការយល់ព្រមអនុញ្ញាតរបស់ក្រសួងសុខាភិបាល

-ឬការផ្សព្វផ្សាយនោះអាចបង្កបាតុភាពមិនល្អផ្សេងៗ ។

**ប្រការ១៣.-** ការប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពី ការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។

**ប្រការ១៤.-** ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល-អគ្គាធិការដ្ឋាន-គណៈវិជ្ជាជីវៈនីមួយៗ នៃខេត្តក្រុង នាយកដ្ឋានមន្ទីរពេទ្យ និង មន្ទីរសុខាភិបាលខេត្ត-ក្រុង មានភារៈកិច្ចត្រួតពិនិត្យតាមដានការអនុវត្តន៍ ប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល៖
-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា-រដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រសួងពាក់ព័ន្ធ ដើម្បីសហការ
-សាលាក្រុងភ្នំពេញ និង គ្រប់ខេត្តក្រុង
ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ
-ដូចប្រការ ១៤
-ឯកសារ-កាលប្បវត្តិ

បណ្ឌ. នុត សុខុម